ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ១-កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍

| | |
|---|---|
| ឈ្មោះសហគមន៍នេសាទ | : **ល្បៀត** |
| ភូមិ | : ល្បៀត |
| ឃុំ | : ជ្រោយបន្ទាយ |
| ស្រុក | : ព្រែកប្រសព្វ |
| ខេត្ត | : ក្រចេះ |

# បញ្ជីអត្ថបទ

១~ កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍

២~ ផែនទីកន្លែងនេសាទសហគមន៍

៣~ បញ្ជីឈ្មោះសមាជិក គណៈកម្មការសហគមន៍ និងរចនាសម្ព័ន្ធ

៤~ លក្ខន្តិកៈសហគមន៍នេសាទ

៥~ បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

៦~ សេចក្តីថ្លែងការណ៍នៃការបង្កើតសហគមន៍នេសាទ

៧~ ឯកសារផ្សេងៗ

# កិច្ចព្រមព្រៀង

## កន្លែងនេសាទសហគមន៍

---

**រ វា ង**

នាយខណ្ឌរដ្ឋបាលជលផល ក្រចេះ ជាតំណាងស្របច្បាប់នៃរដ្ឋបាលជលផល មានអាស័យដ្ឋាននៅ : ភូមិក្រចេះ សង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ ទូរស័ព្ទលេខ ០១២ ៦៧៤ ៨៨៩ និង ទូរសារលេខ .....................ហៅថា "ភាគី **ក** "។

**និង**

ប្រធានគណៈកម្មការសហគមន៍នេសាទ **ល្បៀត** ជាតំណាងស្របច្បាប់ឱ្យសហគមន៍នេសាទដែលមានអាសយដ្ឋានស្ថិតនៅភូមិល្បៀត ឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ទូរស័ព្ទលេខ ...................................... (ប្រធានគណៈកម្មការសហគមន៍ នេសាទ) ហៅថា " ភាគី **ខ** " ។

ភាគីទាំងពីរបានឯកភាពគ្នាចុះកិច្ចព្រមព្រៀងតាមលក្ខខណ្ឌដូចខាងក្រោម:

**ប្រការ ១.-**

ភាគី **ក** ប្រគល់ដែននេសាទដែលជាទ្រព្យសម្បត្តិរបស់រដ្ឋឱ្យភាគី **ខ** ធ្វើការគ្រប់គ្រង ការពារ អភិរក្ស អភិវឌ្ឍន៍ និង ប្រើប្រាស់ធនធានជលផលរយៈពេល ៣ ឆ្នាំ ចាប់ពីថ្ងៃទី..01....ខែ..មករា..ឆ្នាំ ២០10......រហូតដល់ថ្ងៃទី..01... ខែ..មករា..ឆ្នាំ ២០13.... ដោយធានានូវចីរភាពតាមរយៈការរៀបចំសហគមន៍នេសាទ។

**ប្រការ ២.-**

ដែននេសាទនេះមានឈ្មោះថា "**កន្លែងនេសាទសហគមន៍ល្បៀត**" ដែលលាតសន្ធឹងនៅក្នុង

-ភូមិល្បៀត ឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ ខេត្ត ក្រចេះ។

មាននិយាមការដូចខាងក្រោម :

| **ចំនុចទីតាំង** | **ចំនុចអាប់ស៊ីស** | **ចំនុចអ័រដោនេ** |
|---|---|---|
| ជ្រុងខាងត្បូងវត្តនេនធន | ០៦០៩៤៨៨ | ១៣៩១៨០៩ |
| ទួលស្រែជ្រៃ | ០៦០៨៩០៤ | ១៣៩២០៧០ |
| ទួលស្រែកោះកេង | ០៦០៨៦៧០ | ១៣៩១៩៨៩ |
| ដីចៀមសុខ (ដំបូកដើមស្ដៅ) | ០៦០៨១៣១ | ១៣៩២០៩៧ |
| ទួលអូររំចេក | ០៦០៧៨៧៦ | ១៣៩១៨៧៣ |
| ក្បាលអូររំចេកដីស្រែ ប្រេះឡញ | ០៦០៧៨២០ | ១៣៩១៧៣០ |
| ស្រែអូរជ្រៃ ដីធូ ផល្លី | ០៦០៩០៩៦ | ១៣៩២០៥៥ |

| | | |
|---|---|---|
| ព្រំដី រស់ ជា | ០៦០៩២៨៩ | ១៣៩១០៤៥ |
| ដីស្រែរស់ ជា | ០៦០៨៧០៧ | ១៣៩០៤២៥ |
| ជាប់របងវិទ្យាល័យជ្រោយបន្ទាយ | ០៦០៨០៨៩ | ១៣៩០៦៣៣ |

ដូចមានផែនទីដែលបានភ្ជាប់មកជាមួយ។

**ប្រការ ៣.-**

ភាគី **ក** ត្រូវបំពេញភារកិច្ចជាអ្នកជួយសម្របសម្រួល ផ្តល់បច្ចេកទេស ទប់ស្កាត់បទល្មើស តាមដាន និង ត្រួតពិនិត្យលើការរៀបចំ និងការប្រព្រឹត្តទៅរបស់សហគមន៍នេសាទដូចមានចែងនៅក្នុងមាត្រា ២៣ នៃអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ។

**ប្រការ ៤.-**

ភាគី **ខ** ត្រូវរៀបចំ :

- កន្លែងអភិរក្សព្រៃលិចទឹក
- កន្លែងអភិរក្សអន្លង់ត្រីមេពូជ
- កន្លែងអភិរក្សជីវចំរុះ
- ស្តារប្រឡាយ ព្រែក បឹង ស្រះ
- ដាំព្រៃលិចទឹក
- ធ្វើវារីវប្បកម្ម
- បញ្ជូនសមាជិកសហគមន៍ដើម្បីរៀនសូត្រនូវបច្ចេកទេសផលិតពូជត្រី
- ការងារអភិវឌ្ឍន៍ផ្សេងៗទៀត។

**ប្រការ ៥.-**

ភាគី **ខ** ត្រូវរៀបចំប្រជុំពិភាក្សាអំពីទំហំ ចំនួន ប្រវែង និង ប្រភេទឧបករណ៍នេសាទ ដែលអនុញ្ញាតឱ្យប្រើប្រាស់នៅក្នុងកន្លែងនេសាទសហគមន៍ ឱ្យសមស្របតាមស្ថានភាពភូមិសាស្ត្រ និង ពេលវេលា ផ្អែកតាមច្បាប់ស្តីពីជលផល និង លិខិតបង្គាប់គតិយុត្តិនានាដែលពាក់ព័ន្ធ។

**ប្រការ ៦.-**

ភាគី **ខ** មានភារកិច្ចថែរក្សាការពារធនធានធម្មជាតិដូចខាងក្រោម :

-ការពារព្រៃលិចទឹកដែលមានស្រាប់ឱ្យបានគង់វង្ស ចាត់វិធានការទប់ស្កាត់ និងបង្ការភ្លើងឆេះព្រៃ

- រក្សា និង ការពារដីទំនាបលិចទឹកសម្រាប់ដាំព្រៃលិចទឹកឡើងវិញ
- លែងទៅក្នុងធម្មជាតិវិញនូវវារីសត្វដែលកំពុងរងគ្រោះថ្នាក់ជិតផុតពូជ នៅពេលដែលធ្វើនេសាទបាន
- ការពារសត្វព្រៃគ្រប់ប្រភេទនៅក្នុងដែននេសាទ ឬ ព្រៃលិចទឹក។

## ប្រការ ៧._

ភាគី ២ មិនត្រូវធ្វើសកម្មភាពដែលបង្កឱ្យខូចដែននេសាទ ឬ គ្រោះថ្នាក់ដល់ធនធានជលផលដូចខាងក្រោម :

- ចាប់នូវធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ ដូចមានចែងក្នុងប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដូចជាផ្សោត ត្រីគល់រាំង ត្រីរាជជាដើម ។
- លើកទំនប់ លុប ឬជីក បឹង ព្រែក ប្រឡាយ រណ្តៅ ប្បៀ ស្រះ ដែលពុំមានការអនុញ្ញាតពីស្ថាប័នជំនាញ
- កាប់ ឆ្ការ គាស់ រាន ឈូសឆាយ ព្រៃលិចទឹក ក្នុងគោលបំណងហ៊ុំព័ទ្ធយកដីជាកម្មសិទ្ធិ ឬវាត ដីធ្វើស្រែចំការ ឬ គោលបំណងផ្សេងៗឡើយ ។
- ធ្វើនេសាទ កាប់ព្រៃ ឬ អុសក្នុងកន្លែងអភិរក្សជលផល ក្នុងកន្លែងនេសាទសហគមន៍
- ប្រើប្រាស់ឧបករណ៍ហាមឃាត់ ជាពិសេសឧបករណ៍នេសាទឆក់ត្រី និង ឧបករណ៍នេសាទស្បៃមុងគ្រប់ប្រភេទ
- ប្រើប្រាស់ឧបករណ៍នេសាទខុសពីការកំណត់នៅក្នុងតារាងឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះ
- ចិញ្ចឹមត្រី ឬធ្វើស្រែប្រាំងប្រើថ្នាំសម្លាប់ស្មៅ ឬសត្វល្អិត ឬការបំពុលបរិស្ថានផ្សេងៗដែលនាំឱ្យខូចដល់បរិស្ថានធម្មជាតិ សុខភាព និងបំផ្លិចបំផ្លាញដល់ធនធានជលផល ឬ បង្ក អន្តរាយដល់ដែននេសាទ ។
- ផលិត ទិញ លក់ ដឹកជញ្ជូន រក្សាទុកឧបករណ៍ឆក់ ឧបករណ៍នេសាទស្បៃមុងគ្រប់ប្រភេទ និង អួនអូសទឹកសាប
- ដាក់សម្រាស់ ឬមធ្យោបាយផ្សេងទៀតធ្វើឱ្យត្រី ឬវារីសត្វកុំសម្រាប់ចាប់
- ដាំ ឬ ថែរក្សាដំណាំឈូកក្នុងដែននេសាទ
- ធ្វើនេសាទដោយមង ឬអួនអូសគ្រប់ប្រភេទដែលមានក្រឡាតូចជាងមួយសង្ទីម៉ែត្រកន្លះ (១.៥ស.ម) និងធំជាងដប់ប្រាំសង្ទីម៉ែត្រ (១៥ ស.ម) ក្នុងដែននេសាទទឹកសាប ។

## ប្រការ ៨._

ភាគី ២ ត្រូវចាត់វិធានការថែរក្សាការពារកន្លែងនេសាទសហគមន៍ដោយបំផុស ជំរុញ និង លើកទឹកចិត្តដល់សមាជិកសហគមន៍នេសាទគ្រប់រូប ឱ្យរាយការណ៍ទៅសមត្ថកិច្ចរដ្ឋបាលជលផលដែលនៅជិតបំផុត ដើម្បីសហការទប់ស្កាត់បទល្មើសជលផល ។

## ប្រការ ៩._

ភាគី ២ ត្រូវអនុវត្តនូវភារកិច្ចដូចខាងក្រោម:

- ប្រតិបត្តិយ៉ាងម៉ឺងម៉ាត់តាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និង ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- ធានាឱ្យសមាជិកទាំងអស់ក្នុងសហគមន៍មានសិទ្ធិស្មើគ្នាលើការប្រើប្រាស់ធនធានជលផល
- សហការយ៉ាងជិតស្និតជាមួយរដ្ឋបាលជលផល ក្រុមប្រឹក្សាឃុំ សង្កាត់ និងអាជ្ញាធរដែលពាក់ព័ន្ធ ។

**ប្រការ ១០._**

ប្រសិនភាគី ខ មិនអនុវត្តទៅតាមប្រការទាំងឡាយនៃកិច្ចព្រមព្រៀងនេះ ធ្វើឱ្យអន្តរាយដល់ដែននេសាទ ឬធនធានជលផលត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

**ប្រការ ១១._**

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍អាចបញ្ឈប់មុនពេលកំណត់ដោយផ្អែកលើលក្ខខណ្ឌណាមួយដូចមានចែងក្នុងមាត្រា ២៧ នៃអនុក្រឹត្យ លេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ។

ក្នុងករណីដែលសហគមន៍នេសាទយល់ថា ការបញ្ឈប់កិច្ចព្រមព្រៀងពុំមានលក្ខណៈសមស្រប សហគមន៍នេសាទអាចធ្វើការតវ៉ាមកប្រធានរដ្ឋបាលជលផលថ្នាក់កណ្តាល។

**ប្រការ ១២._**

កិច្ចព្រមព្រៀងនេះអាចធ្វើការកែប្រែបានតាមការឯកភាពរបស់ភាគីទាំង ២ ស្របតាមច្បាប់ និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងសហគមន៍នេសាទ។

កិច្ចព្រមព្រៀងនេះ ត្រូវតម្កល់ទុកនៅស្នាក់ការសហគមន៍នេសាទ សាលាឃុំ សង្កាត់ ខណ្ឌរដ្ឋបាលជលផល សាលាខេត្ត ក្រុង រដ្ឋបាលជលផលថ្នាក់កណ្តាល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយអាចចម្លងជូនស្ថាប័នពាក់ព័ន្ធ ដោយច្បាប់ចម្លងត្រូវមានប្រថាប់ត្រា។

ថ្ងៃទី...២៦...... ខែ សីហា...ឆ្នាំ ..២០០៩.....

**ភាគី ក**

**នាយខណ្ឌរដ្ឋបាលជលផលក្រចេះ**

ហត្ថលេខា

**សៀង_គីន**

ថ្ងៃទី...២៦.... ខែ .សីហា..ឆ្នាំ ២០០៩......

**ភាគី ខ**

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

ហត្ថលេខា

**សាក្សី**

**មេឃុំ ជ្រោយបន្ទាយ**

ហត្ថលេខា

**ឡាច_គីមរឿ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ២_ផែនទីកន្លែងនេសាទសហគមន៍

ឈ្មោះសហគមន៍នេសាទ : **ល្បៀត**

ភូមិ : ល្បៀត

ឃុំ : ជ្រោយបន្ទាយ

ស្រុក : ព្រែកប្រសព្វ

ខេត្ត : ក្រចេះ




## សញ្ញាសំគាល់

- ព្រំប្រទល់កន្លែងនេសាទសហគមន៍
- វាលស្រែ
- ព្រៃឈើស្តើង
- ព្រៃឈើក្រាស់
- កំពស់គិតជាម៉ែត្រ
- ខ្សែរយ:កំពស់
- ឆ្នេរខ្សាច់
- ទន្លេ, ព្រែក, ស្ទឹង, អូរ
- មណ្ឌលសុខភាព, មន្ទីរពេទ្យ
- ផ្លូវលំ
- ផ្លូវជាតិលេខ ៧
- ទំនប់ដីលើក
- បឹង, ត្រពាំងទឹកដក់ខួប
- បឹង, ត្រពាំងទឹកដក់មិនខួប
- សាលារៀន, វត្ត
- ដីចំការ
- ផ្ទះ, ភូមិ

ផ្ទៃក្រឡា : ១៩៨ ហិកតា

មាត្រដ្ឋាន ១/ ៥០០០០

COORDENATION SYSTEM
- Projection :................ UTM
- Zone : ....................... 48 N
- Datum :............... Indian 60
- Spheroid :.............. Everest
- Unit :....................... Meter

០ ១ ២គម




# ផែនទីកន្លែងនេសាទសហគមន៍ល្បៀត
# ឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ

លេខ ២៩ ៨/០៩

បានឃើញ និងបញ្ជូនមក

លោកអភិបាលស្រុកព្រែកប្រសព្វ "ដើម្បីពិនិត្យ និងសម្រួល"

..........ថ្ងៃទី.......ខែ..........ឆ្នាំ ២០០៩

មេឃុំជ្រោយបន្ទាយ

ឡុង_គីមអ៊ី

បានឃើញ និងបញ្ជូនមក

លោកមេឃុំជ្រោយបន្ទាយ "ដើម្បីពិនិត្យ និងសម្រួល" ..........ថ្ងៃទី.......ខែ..........ឆ្នាំ ២០០៩

មេភូមិ.........

បានឃើញ និងបញ្ជូនមក

លោកមេភូមិ.........."ដើម្បីពិនិត្យ និងសម្រួល" ..........ថ្ងៃទី.......ខែ..........ឆ្នាំ ២០០៩

ប្រធានគណ:កម្មការសហគមន៍នេសាទល្បៀត

អែម សុជាត

លេខ :.........

បានឃើញ និងបញ្ជូនមក

នាយអធិការដ្ឋានរដ្ឋបាលជលផលមេគង្គ "ដើម្បីពិនិត្យ និងសម្រួល"

..........ថ្ងៃទី.......ខែ..........ឆ្នាំ ២០០៩

នាយខណ្ឌរដ្ឋបាលជលផលក្រចេះ

ស៊ឿន_គិន

លេខ :.........

បានឃើញ និងបញ្ជូនមក

នាយខណ្ឌរដ្ឋបាលជលផលក្រចេះ "ដើម្បីពិនិត្យ និងសម្រួល"

..........ថ្ងៃទី.......ខែ..........ឆ្នាំ ២០០៩

អភិបាលស្រុកព្រែកប្រសព្វ

ម៉ា ជុន

លេខ :.........

បានឃើញ និងគោរពជូន

ឯកឧត្តមអភិបាលខេត្តក្រចេះ "ដើម្បីពិនិត្យ និងសម្រួល"

..........ថ្ងៃទី.......ខែ..........ឆ្នាំ ២០០៩

អធិការដ្ឋានរដ្ឋបាលជលផលមេគង្គ

ឡុង_គន

លេខ :.........

បានឃើញ និងបញ្ជូនមក

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល "ដើម្បីពិនិត្យ និងសម្រួល"

..........ថ្ងៃទី.......ខែ..........ឆ្នាំ ២០០៩

អភិបាលខេត្តក្រចេះ

ខាំ_ភឿន

លេខ :.........កសក

បានឃើញ និងបញ្ជូនមក

ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

"ដើម្បីពិនិត្យ និងសម្រេច"

..........ថ្ងៃទី.......ខែ..........ឆ្នាំ ២០១០

ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

បានឃើញ និងឯកភាព

ភ្នំពេញ,ថ្ងៃទី.......ខែ..........ឆ្នាំ ២០១០

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

រដ្ឋលេខាធិការ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ៣-បញ្ជីឈ្មោះសមាជិក គណៈកម្មការសហគមន៍នេសាទ និងរចនាសម្ព័ន្ធ

ឈ្មោះសហគមន៍នេសាទ : **ល្បៀត**

ភូមិ : ល្បៀត

ឃុំ : ជ្រោយបន្ទាយ

ស្រុក : ព្រែកប្រសព្វ

ខេត្ត : ក្រចេះ

# បញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ ល្បៀត

## ភូមិល្បៀត ឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ

ចំនួនប្រជាជន គ្រួសារ

ចំនួនមនុស្សអាយុចាប់ពី ១៨ឆ្នាំឡើងទៅ នាក់ ស្រី នាក់

ចំនួនសមាជិកសហគមន៍នេសាទ 176 នាក់ ស្រី 69 នាក់ ស្មើនឹង ភាគរយ

| ល.រ | ឈ្មោះសមាជិក | ភេទ | អាយុ | ភូមិ | សង្កាត់ | ក្រុង | មុខរបរ | ថ្ងៃ ខែ ឆ្នាំចូលជាសមាជិក |
|---|---|---|---|---|---|---|---|---|
| ១ | ស្រី សុខណា | ស្រី | ៤២ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ១៥/០៧/២០០៩ |
| ២ | ផង់ ចូត | ប្រុស | ៤៨ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ នេសាទ | ៣១/០៥/២០០៩ |
| ៣ | សាច ស៊ីម | ប្រុស | ៣៦ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ នេសាទ | ១២/០៦/២០០៩ |
| ៤ | កែម ផន | ប្រុស | ៣៩ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ នេសាទ | ១៤/០៦/២០០៩ |
| ៥ | សោម វ៉ាឌី | ប្រុស | ៤៤ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ១៤/០៦/២០០៩ |
| ៦ | អិន មេ | ប្រុស | ៣០ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ នេសាទ | ១៤/០៦/២០០៩ |
| ៧ | ឡឹក សារឿន | ស្រី | ២៤ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ១៤/០៦/២០០៩ |
| ៨ | ហ៊ាន ហឿន | ប្រុស | ៣៣ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ១៥/០៧/២០០៩ |
| ៩ | ស៊ាម ភួន | ប្រុស | ១៨ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | នេសាទ | ១៥/០៧/២០០៩ |
| ១០ | ស៊ាម ភិន | ប្រុស | ២៧ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ នេសាទ | ១១/០៦/២០០៩ |
| ១១ | សាត ថុល | ប្រុស | ៣៩ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ នេសាទ | ១១/០៦/២០០៩ |
| ១២ | ឆន ឈុនលី | ស្រី | ៤៨ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ១០/០៦/២០០៩ |
| ១៣ | ស៊ាម រ៉ុង | ប្រុស | ៣៩ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ នេសាទ | ១០/០៦/២០០៩ |
| ១៤ | ស៊ុន សាំងលីម | ស្រី | ៣៨ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើចំការ | ១០/០៦/២០០៩ |
| ១៥ | ផង ម៉ុត | ប្រុស | ៤៥ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ នេសាទ | ១៤/០៧/២០០៩ |
| ១៦ | ហាស់ វីរៈ | ប្រុស | ៤៨ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ នេសាទ | ១៤/០៧/២០០៩ |
| ១៧ | ប៉ែន យុន | ប្រុស | ៤៨ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ នេសាទ | ១៤/០៧/២០០៩ |
| ១៨ | តៃ ស៊ាន | ប្រុស | ២៦ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ នេសាទ | ១៤/០៦/២០០៩ |
| ១៩ | សេង ប្រុស | ប្រុស | ៣៩ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ពេទ្យសត្វ | ១០/០៦/២០០៩ |
| ២០ | ស៊ឹម យឿង | ប្រុស | ៥៩ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ១០/០៦/២០០៩ |
| ២១ | ភន ទូច | ស្រី | ២២ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ១៥/០៧/២០០៩ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ២២ | ហ៊ាន ហឿន | ប្រុស | ៣៣ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ១៥/០៧/២០០៩ |
| ២៣ | ជួន ឡុង | ប្រុស | ២៨ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ១៥/០៧/២០០៩ |
| ២៤ | សំ ស៊ាងអ៊ុយ | ស្រី | ២៤ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ១៣/០៧/២០០៩ |
| ២៥ | ហែម សឿន | ស្រី | ៥៩ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ១៥/០៧/២០០៩ |
| ២៦ | ភន ដានី | ប្រុស | ១៩ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ១៣/០៧/២០០៩ |
| ២៧ | ឆន ឈុនអ៊ី | ស្រី | ៥០ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ១៣/០៧/២០០៩ |
| ២៨ | រស់ គុង | ប្រុស | ៤៩ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ នេសាទ | ១០/០៦/២០០៩ |
| ២៩ | ម៉ែន ប៊ុនថន | ប្រុស | ៤៣ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ១៣/០៧/២០០៩ |
| ៣០ | នួន ចេន | ស្រី | ៤២ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ១៣/០៧/២០០៩ |
| ៣១ | ឌឹម ណាន | ប្រុស | ២៣ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ១៣/០៧/២០០៩ |
| ៣២ | អ៊ុំ ធា | ប្រុស | ៣៥ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ១៣/០៦/២០០៩ |
| ៣៣ | កែម សុខមី | ស្រី | ១៩ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ១៣/០៧/២០០៩ |
| ៣៤ | អ៊ុល មុំ | ស្រី | ៥១ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ១៣/០៧/២០០៩ |
| ៣៥ | ម៉ៅ មាន | ប្រុស | ៥១ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៧/០៦/២០០៩ |
| ៣៦ | ប៊ុន ប៊ុនធឿន | ប្រុស | ៣៤ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ៣១/០៥/២០០៩ |
| ៣៧ | សេន ម៉ៅ | ប្រុស | ៥៤ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើចំការ | ០៧/០៦/២០០៩ |
| ៣៨ | សាត សៀក | ប្រុស | ២៨ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ ចំការ | ០៧/០៦/២០០៩ |
| ៣៩ | រស់ អឿន | ប្រុស | ៥៧ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ ចំការ | ០៧/០៥/២០០៩ |
| ៤០ | អ៊ិន គុល | ប្រុស | ៣១ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ៣០/០៥/២០០៩ |
| ៤១ | កែម ប៊ុនធឿន | ប្រុស | ៣២ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ចិញ្ចឹមជ្រូក | ៣១/០៥/២០០៩ |
| ៤២ | សោម លីណា | ប្រុស | ៤០ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ចិញ្ចឹមជ្រូក លក់ដូរ | ៣១/០៥/២០០៩ |
| ៤៣ | អ៊ិន ទាំង | ប្រុស | ២៣ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ នេសាទ | ៣១/០៥/២០០៩ |
| ៤៤ | កែម សុផាត | ប្រុស | ៤៣ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ នេសាទ | ៣១/០៥/២០០៩ |
| ៤៥ | មូ គីមអោ | ស្រី | ៤៦ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ១៣/០៦/២០០៩ |
| ៤៦ | ឈុំ ផៃនេង | ស្រី | ២៥ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ១២/០៦/២០០៩ |
| ៤៧ | ទី ពន្លក់ | ប្រុស | ២៤ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ នេសាទ | ១២/០៦/២០០៩ |
| ៤៨ | ឡា សុភ័ក្រ | ប្រុស | ១៩ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ នេសាទ | ៣១/០៥/២០០៩ |
| ៤៩ | អ៊ុក កែវ | ប្រុស | ៥៣ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ នេសាទ | ៣០/០៥/២០០៩ |
| ៥០ | អេង សុខន | ស្រី | ៥០ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ១១/០៥/២០០៩ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៥១ | សាត ធឿង | ប្រុស | ៣៥ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ ចំការ | ៣១/០៥/២០០៩ |
| ៥២ | ពាង នឿន | ប្រុស | ៤៥ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ នេសាទ | ០៧/០៦/២០០៩ |
| ៥៣ | រស អ៊ា | ស្រី | ៥១ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ ចំការ | ១០/០៦/២០០៩ |
| ៥៤ | ឆ្វ ប៊ុនឆេង | ប្រុស | ២៣ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ ចំការ | ១១/០៥/២០០៩ |
| ៥៥ | ថៃ សុខខេត | ប្រុស | ២២ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ នេសាទ | ១០/០៦/២០០៩ |
| ៥៦ | ថៃ វ៉ាល | ប្រុស | ៣១ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ នេសាទ | ១០/០៦/២០០៩ |
| ៥៧ | ថៃ ឌីណា | ប្រុស | ២០ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ ចំការ | ១០/០៦/២០០៩ |
| ៥៨ | ស៊ុំ វី | ប្រុស | ២៨ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៧/០៦/២០០៩ |
| ៥៩ | ឡឹក រុន | ប្រុស | ២៨ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ១០/០៦/២០០៩ |
| ៦០ | ឌឹម ពិន | ប្រុស | ៣៧ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ នេសាទ | ០៦/០៦/២០០៩ |
| ៦១ | វៀន មឿន | ប្រុស | ៤៥ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ ចំការ | ០៧/០៦/២០០៩ |
| ៦២ | មុិល ភឿន | ប្រុស | ២៩ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ នេសាទ | ១០/០៦/២០០៩ |
| ៦៣ | ជុំ វឿន | ប្រុស | ៤៩ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ ចំការ | ១០/០៦/២០០៩ |
| ៦៤ | វិត វី | ប្រុស | ២៥ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ១០/០៦/២០០៩ |
| ៦៥ | គាំ ហេន | ស្រី | ៤៧ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ១០/០៦/២០០៩ |
| ៦៦ | ពាង វ៉ាត | ប្រុស | ៣៥ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ ចំការ | ១០/០៦/២០០៩ |
| ៦៧ | រស់ ហុង | ប្រុស | ៣៦ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ នេសាទ | ១០/០៦/២០០៩ |
| ៦៨ | លុយ ផង | ស្រី | ២៣ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ១០/០៦/២០០៩ |
| ៦៩ | ផង មីន | ប្រុស | ៦០ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ១៣/០៧/២០០៩ |
| ៧០ | ភន ហ៊ី | ប្រុស | ៣០ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ១៣/០៧/២០០៩ |
| ៧១ | ប៉ែន សុខនី | ស្រី | ២៥ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ១៣/០៧/២០០៩ |
| ៧២ | នួន ម៉ៃ | ប្រុស | ៣៦ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ១៣/០៧/២០០៩ |
| ៧៣ | សោម ចាន់នី | ស្រី | ៣០ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ១៣/០៧/២០០៩ |
| ៧៤ | អ៊ុក យេង | ស្រី | ៦៤ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | នៅផ្ទះ | ១៣/០៧/២០០៩ |
| ៧៥ | ហ៊ីង គាំងអួច | ស្រី | ២៦ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ១៣/០៧/២០០៩ |
| ៧៦ | កែម ផេង | ប្រុស | ៤៨ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ១៣/០៧/២០០៩ |
| ៧៧ | ឈាង ឡែន | ប្រុស | ២៩ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ១៣/០៧/២០០៩ |
| ៧៨ | ស៊ាម តូនី | ប្រុស | ២២ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ១៣/០៧/២០០៩ |
| ៧៩ | ស៊ាម សុភាង | ស្រី | ៣០ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ១៣/០៧/២០០៩ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៨០ | ឆេន ស្រីជូ | ស្រី | ២១ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ១៣/០៧/២០០៩ |
| ៨១ | គីន ប៉ាង | ប្រុស | ៣៨ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ១៣/០៧/២០០៩ |
| ៨២ | ឆេន ជុំ | ស្រី | ៣២ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៥/០៨/២០០៩ |
| ៨៣ | ឆេន មុំ | ស្រី | ២៦ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៥/០៨/២០០៩ |
| ៨៤ | អ៊ុក តូ | ស្រី | ៥០ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៥/០៨/២០០៩ |
| ៨៥ | សេង ម៉ានី | ស្រី | ២៥ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៥/០៨/២០០៩ |
| ៨៦ | អ៊ុម សី | ប្រុស | ៥១ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៦/០៨/២០០៩ |
| ៨៧ | សេង ណាល់ | ប្រុស | ២៤ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៣/០៨/២០០៩ |
| ៨៨ | គាន ឡាយ | ស្រី | ២៥ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៥/០៨/២០០៩ |
| ៨៩ | នង មីន | ស្រី | ២៥ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៦/០៨/២០០៩ |
| ៩០ | ហាម ហួត | ប្រុស | ៣០ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៥/០៨/២០០៩ |
| ៩១ | កែវ ឈីម | ប្រុស | ៣០ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៥/០៨/២០០៩ |
| ៩២ | ហាម ខែន | ស្រី | ២៦ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៣/០៨/២០០៩ |
| ៩៣ | ព្រុំ សេត | ប្រុស | ៥១ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០២/០៨/២០០៩ |
| ៩៤ | រស់ អុន | ស្រី | ៤៦ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០២/០៨/២០០៩ |
| ៩៥ | វន ស៊ាង | ប្រុស | ២១ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០២/០៨/២០០៩ |
| ៩៦ | វន សារ | ប្រុស | ២៤ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០២/០៦/២០០៩ |
| ៩៧ | វន សេង | ស្រី | ២៣ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៣/០៦/២០០៩ |
| ៩៨ | កែម សេង | ប្រុស | ២៨ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៣/០៦/២០០៩ |
| ៩៩ | ហែប តាប់ | ប្រុស | ៣៩ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៣/០៦/២០០៩ |
| ១០០ | ធូ អុល | ស្រី | ៤១ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៥/០៧/២០០៩ |
| ១០១ | ម គ្រុយ | ប្រុស | ១៨ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៥/០៧/២០០៩ |
| ១០២ | កែម សាវ៉ាត | ស្រី | ២៩ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៥/០៧/២០០៩ |
| ១០៣ | ធូ តិះ | ប្រុស | ៣៣ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៥/០៧/២០០៩ |
| ១០៤ | ជិន មឿន | ប្រុស | ៣៣ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | នៅផ្ទះ | ០៣/០៨/២០០៩ |
| ១០៥ | ជួប ស៊ីថា | ស្រី | ២៥ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៥/០៧/២០០៩ |
| ១០៦ | ឆេន ចាន់ | ប្រុស | ១៨ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៦/០៧/២០០៩ |
| ១០៧ | ជិន ថេត | ស្រី | ២៤ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៦/០៧/២០០៩ |
| ១០៨ | សំ ជឿន | ស្រី | ២២ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៥/០៨/២០០៩ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ១០៩ | បន ឃីម | ប្រុស | ៣៧ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៣/០៧/២០០៩ |
| ១១០ | កែម ឈាត | ប្រុស | ៣៥ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៦/០៧/២០០៩ |
| ១១១ | សោម រេន | ប្រុស | ៥៦ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៥/០៧/២០០៩ |
| ១១២ | ហែម តាន់ | ប្រុស | ៥១ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៣/០៦/២០០៩ |
| ១១៣ | កាយ កែ | ប្រុស | ៥៨ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៣/០៦/២០០៩ |
| ១១៤ | នង សុវណ្ណ | ប្រុស | ៤៩ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៣/០៦/២០០៩ |
| ១១៥ | អ៊ុក តុន | ប្រុស | ៤៩ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៣/០៧/២០០៩ |
| ១១៦ | សើ ម៉ារ៉ា | ប្រុស | ១៩ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ នេសាទ | ០៣/០៧/២០០៩ |
| ១១៧ | ថោង ម៉ាប់ | ស្រី | ២៥ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ នេសាទ | ០៦/០៧/២០០៩ |
| ១១៨ | ពាង ទី | ប្រុស | ៤៩ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ នេសាទ | ០៦/០៧/២០០៩ |
| ១១៩ | តេង ប៊ុក | ស្រី | ៤៤ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៦/០៧/២០០៩ |
| ១២០ | អ៊ុក ញិប | ស្រី | ៤៣ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ នេសាទ | ០៦/០៧/២០០៩ |
| ១២១ | ឈាង សំណាង | ស្រី | ២៧ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៦/០៧/២០០៩ |
| ១២២ | ម៉ិល ធា | ប្រុស | ៣២ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៣/០៧/២០០៩ |
| ១២៣ | ជួប ជរ | ប្រុស | ៣៤ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៣/០៧/២០០៩ |
| ១២៤ | កែម ឆ្វូ | ស្រី | ២៨ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៣/០៧/២០០៩ |
| ១២៥ | កែម សុខលីន | ស្រី | ២៨ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៣/០៧/២០០៩ |
| ១២៦ | មូល ប៊ីប | ស្រី | ២៣ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៣/០៧/២០០៩ |
| ១២៧ | ខេង ណាំ | ប្រុស | ២៦ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៦/០៨/២០០៩ |
| ១២៨ | មី គ្រឿន | ប្រុស | ៥៥ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | នេសាទ | ០៦/០៨/២០០៩ |
| ១២៩ | សោម អាប | ស្រី | ៤០ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៦/០៨/២០០៩ |
| ១៣០ | សោម សេន | ស្រី | ២៨ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៥/០៨/២០០៩ |
| ១៣១ | កង ពេញ | ប្រុស | ៥៩ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ ចំការ | ០៥/០៨/២០០៩ |
| ១៣២ | សោម អាង | ស្រី | ៤០ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៥/០៨/២០០៩ |
| ១៣៣ | ចាប សុន | ស្រី | ៥១ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ ចំការ | ០៣/០៧/២០០៩ |
| ១៣៤ | ម៉ៅ ជ្រិន | ប្រុស | ៤៨ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ ចំការ | ០៥/០៧/២០០៩ |
| ១៣៥ | សោម រ៉ាវី | ស្រី | ៤៨ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ ចំការ | ០៣/០៧/២០០៩ |
| ១៣៦ | សាយ មឿក | ប្រុស | ២៩ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ ចំការ | ០៣/០៧/២០០៩ |
| ១៣៧ | សាយ ស៊ីណា | ប្រុស | ១៩ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៧/០៧/២០០៩ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ១៣៨ | សាយ ច្រឹប | ស្រី | ២៥ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៣/០៧/២០០៩ |
| ១៣៩ | អ៊ុក ស្រ៊ន | ប្រុស | ៤៨ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ចិញ្ចឹមជ្រូក | ០៣/០៧/២០០៩ |
| ១៤០ | ហែម ស្រាង | ស្រី | ៤៨ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ចិញ្ចឹមជ្រូក | ០៤/០៧/២០០៩ |
| ១៤១ | ជាម សេងហុង | ស្រី | ២៤ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ចិញ្ចឹមជ្រូក | ០៣/០៧/២០០៩ |
| ១៤២ | ជាម ស្រេង | ប្រុស | ២៦ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៣/០៧/២០០៩ |
| ១៤៣ | វ៉ាន ណើយ | ស្រី | ៣៦ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៣/០៧/២០០៩ |
| ១៤៤ | ផន គ្រេន | ប្រុស | ៣៨ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៣/០៧/២០០៩ |
| ១៤៥ | វ៉ាន ណន | ស្រី | ២៨ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៣/០៧/២០០៩ |
| ១៤៦ | ម៉ុល លូត | ប្រុស | ២៣ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ នេសាទ | ០៧/០៧/២០០៩ |
| ១៤៧ | ម៉ុល ជា | ស្រី | ២៥ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៧/០៧/២០០៩ |
| ១៤៨ | ធាវ ឡើប | ស្រី | ៣៩ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៥/០៧/២០០៩ |
| ១៤៩ | ធាវ ស៊ារ | ស្រី | ៣៥ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៣/០៦/២០០៩ |
| ១៥០ | ធាវ ពិន | ស្រី | ៥៥ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៣/០៧/២០០៩ |
| ១៥១ | ពាង នឹម | ប្រុស | ៤៨ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៥/០៨/២០០៩ |
| ១៥២ | ពាង ឡា | ប្រុស | ២៤ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៥/០៨/២០០៩ |
| ១៥៣ | ពាង ទូច | ប្រុស | ២៧ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៥/០៨/២០០៩ |
| ១៥៤ | ប្រេះ ឡូញ | ប្រុស | ៥៩ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៥/០៨/២០០៩ |
| ១៥៥ | ខាត់ វុន | ស្រី | ៤៦ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៥/០៨/២០០៩ |
| ១៥៦ | តែ ជា | ប្រុស | ២៥ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៥/០៨/២០០៩ |
| ១៥៧ | តែ ធា | ប្រុស | ១៩ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | នេសាទ | ០៥/០៨/២០០៩ |
| ១៥៨ | ឃឹម ពីលីន | ប្រុស | ២៧ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៥/០៧/២០០៩ |
| ១៥៩ | ពាង ធី | ស្រី | ២៥ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៥/០៧/២០០៩ |
| ១៦០ | ឆេន ពិសិត | ប្រុស | ២៤ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៣/០៧/២០០៩ |
| ១៦១ | ឆេន កុសល | ប្រុស | ១៨ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៣/០៧/២០០៩ |
| ១៦២ | កែម អុំ | ស្រី | ៣២ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | លក់ចាបហួយ | ០៣/០៧/២០០៩ |
| ១៦៣ | ឃឹម ប៉ុងលី | ប្រុស | ៣២ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ ចំការ | ០៣/០៧/២០០៩ |
| ១៦៤ | សាយ ផន់ | ស្រី | ២៩ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ ចំការ | ០៦/០៧/២០០៩ |
| ១៦៥ | សាយ ផាន់ណូ | ស្រី | ២៦ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ ចំការ | ០៦/០៧/២០០៩ |
| ១៦៦ | ជួន គុប | ស្រី | ៣២ | ល្បើត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៦/០៧/២០០៩ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ១៦៧ | សាត ផុល | ប្រុស | ៣២ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៣/០៧/២០០៩ |
| ១៦៨ | អ៊ាង សុខនី | ស្រី | ១៩ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ នេសាទ | ០៥/០៧/២០០៩ |
| ១៦៩ | អ៊ាង សុខដា | ស្រី | ១៨ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៥/០៧/២០០៩ |
| ១៧០ | ច្រិក ខុន | ប្រុស | ៣២ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ នេសាទ | ០៥/០៧/២០០៩ |
| ១៧១ | សាម សាវ៉ាន់ | ស្រី | ២៨ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ស្រែ ចំការ | ០៥/០៧/២០០៩ |
| ១៧២ | ពាង សុខលី | ប្រុស | ១៨ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ នេសាទ | ០៥/០៧/២០០៩ |
| ១៧៣ | ចែម សុភ័ក្រ | ប្រុស | ៣៤ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ នេសាទ | ០៥/០៧/២០០៩ |
| ១៧៤ | នុត ចាន់ចាង | ស្រី | ៣៥ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ ចំការ | ០៥/០៧/២០០៩ |
| ១៧៥ | ធូ ចាន់លី | ប្រុស | ៣២ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ ចំការ | ០៦/០៨/២០០៩ |
| ១៧៦ | ថោង ជើង | ស្រី | ៤៦ | ល្បៀត | ជ្រោយបន្ទាយ | ព្រែកប្រសព្វ | ធ្វើស្រែ | ០៦/០៨/២០០៩ |

ភូមិល្បៀត, ថ្ងៃទី...១...ខែ...ធ្នូ......ឆ្នាំ ២០០៩

អ្នកធ្វើតារាង

**ប្រធានសហគមន៍នេសាទល្បៀត**

ទេវ សុខន

លេខ: ................

ប្រជាជនចំនួន 176 នាក់ ស្រី 69 នាក់ រស់នៅភូមិល្បៀត

ពិតជាបានចុះឈ្មោះ ចូលជាសមាជិកសហគមន៍នេសាទភូមិល្បៀត

ពិតប្រាកដមែន ។

ជ្រោយបន្ទាយ, ថ្ងៃទី...២១.....ខែ...ធ្នូ........ឆ្នាំ ២០០៩

មេឃុំជ្រោយបន្ទាយ

ឡុង_គីមអ៊ី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# បញ្ជីឈ្មោះគណៈកម្មការសហគមន៍នេសាទ ល្បៀត
# ភូមិល្បៀត ឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ

| ល.រ | ឈ្មោះ | ភេទ | អាយុ | ភូមិ | តួនាទីគណៈកម្មការ |
|---|---|---|---|---|---|
| ១ | ស្រី សុខណា | ស្រី | ៤២ | ល្បៀត | ប្រធានគណៈកម្មការសហគមន៍នេសាទ |
| ២ | អេង សុខន | ស្រី | ៥៣ | ល្បៀត | អនុប្រធានទី ១ |
| ៣ | មៃ ទូច | ប្រុស | ៣៧ | ល្បៀត | អនុប្រធានទី ២ |
| ៤ | ធូ តក់ | ប្រុស | ៤១ | ល្បៀត | លេខាធិការ |
| ៥ | ស៊ីន លីប | ស្រី | ៣៩ | ល្បៀត | បេឡាធិការ |
| ៦ | រស់ តុង | ប្រុស | ៣៨ | ល្បៀត | អប់រំផ្សព្វផ្សាយ |
| ៧ | ព្រំ យី | ស្រី | ៥២ | ល្បៀត | អប់រំផ្សព្វផ្សាយ |
| ៨ | ហែម តាន់ | ប្រុស | ៥០ | ល្បៀត | ប្រធានក្រុមល្បាត |
| ៩ | សាទ ជឿន | ប្រុស | ៣៤ | ល្បៀត | អនុប្រធានក្រុមល្បាត |
| ១០ | អ៊ុក សុខ | ប្រុស | ៣៧ | ល្បៀត | សមាជិកល្បាត |
| ១១ | កែវ ធូ | ប្រុស | ២៧ | ល្បៀត | សមាជិកល្បាត |

ធ្វើនៅ...ល្បៀត...ថ្ងៃទី 18...ខែ ធ្នូ...ឆ្នាំ ២០០៩

ប្រធានគណៈកម្មការសហគមន៍នេសាទ...ល្បៀត

បានឃើញ និង បញ្ជាក់ថា

ឈ្មោះនៅក្នុងបញ្ជីខាងលើនេះគឺជាសមាជិកគណៈកម្មការ

សហគមន៍នេសាទ.....ល្បៀត...........ពិតប្រាកដមែន ។

ធ្វើនៅ ជ្រោយបន្ទាយ ថ្ងៃទី 21 ខែ ធ្នូ......ឆ្នាំ ២០០៩

មេឃុំ ជ្រោយបន្ទាយ

# រចនាសម្ព័ន្ធគណៈកម្មការសហគមន៍នេសាទ ល្មៀត
# ភូមិល្មៀត ឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ

**ប្រធាន**
អ្នកស្រី ស្រី សុខណា

**អនុប្រធានទី ១**
អ្នកស្រី អេង សុខន

**អនុប្រធានទី ២**
លោក ម៉ៃ ទូច

**អប់រំ ផ្សព្វផ្សាយ**
លោក រស់ តុង
អ្នកស្រី ព្រំ យី

**បេឡាធិការ**
អ្នកស្រី ស៊ីមលីប

**លេខាធិការ**
លោក ធូ ឆក់

**ផ្នែកល្បាត**
លោក ហែម តាន់ ប្រធាន
លោក សាន ជឿន អនុប្រធាន
លោក អ៊ុំ សុខ ស[redacted]ក
លោក កែវ ធូ ស[redacted]ក

## តួនាទី និងភារកិច្ចទទួលខុសត្រូវរបស់គណៈកម្មការសហគមន៍នេសាទ

### ១-ប្រធានគណៈកម្មការសហគមន៍នេសាទ

- *ដឹកនាំ និងទទួលខុសត្រូវរួមក្នុងការអនុវត្តទីការងារនៅក្នុងសហគមន៍នេសាទ*
- *សម្របសម្រួលការងារជាមួយស្ថាប័នជំនាញ និងអាជ្ញាធរមូលដ្ឋាន ដើម្បីគាំទ្រដល់ការងារសហគមន៍*
- *ទំនាក់ទំនងជាមួយអង្គការនានា ដើម្បីស្វែងរកជំនួនទ្រទ្រង់សកម្មភាពសហគមន៍នេសាទ*
- *សម្របសម្រួលដោះស្រាយបញ្ហាផ្សេងៗក្នុងសហគមន៍នេសាទ*
- *តាមដានត្រួតពិនិត្យរាល់សកម្មភាពការងាររបស់សហគមន៍នេសាទ*
- *ដឹកនាំរាល់ការប្រជុំ និងមហាសន្និបាតក្នុងការបូកសរុបវាយតម្លៃ និងរៀបចំផែនការការងារ*
- *ផ្តល់ភាពយុត្តិធម៌ និងតម្លាភាពដល់សមាជិកសហគមន៍។*

## ២- អនុប្រធានគណៈ[illegible]ការសហគមន៍នេសាទ

- ចូលរួមអនុវត្តការងារជាមួយប្រធាន
- ជំនួសមុខឱ្យប្រធាននៅពេលអវត្តមាន
- អនុប្រធានទី ១ ទទួលបន្ទុកផ្នែកបេឡាធិការ និង អប់រំ ផ្សព្វផ្សាយ
- អនុប្រធានទី ២ ទទួលបន្ទុកផ្នែកលេខាធិកា និង ក្រុមល្បាត ។
- ទទួលភារកិច្ចផ្សេងៗ ដែលប្រធានប្រគល់ជូន ។

## ៣- លេខាធិការ

- កត់ត្រារាល់សកម្មភាព និងរក្សាទុកដាក់ឯកសារផ្សេងៗរបស់សហគមន៍
- ធ្វើកំណត់ហេតុរាល់ការប្រជុំ និងមហាសន្និបាត របស់សហគមន៍នេសាទ
- រៀបចំលិខិតអញ្ជើញ និងទីកន្លែងប្រជុំ
- ទទួលពាក្យស្នើសុំចូលជាសមាជិក និងលាលែងពីសមាជិក
- កត់ត្រា និងគ្រប់គ្រងសម្ភារៈរបស់សហគមន៍នេសាទ
- រៀបចំបែបបទ និងលិខិតស្នាមផ្សេងៗ ដែលទាក់ទងការគ្រប់គ្រងសហគមន៍
- ទទួលពាក្យបណ្តឹងតវ៉ាផ្សេងៗ
- ព្រាងរបាយការណ៍ពីលទ្ធផលការងាររបស់សហគមន៍នេសាទ ដើម្បីដាក់ជូនប្រធានពិនិត្យ និងសម្រេច ។

## ៤- បេឡាធិការ

- ទទួលខុសត្រូវការងារហិរញ្ញវត្ថុរបស់សហគមន៍នេសាទទាំងមូល
- គ្រប់គ្រង និងចុះបញ្ជីគណនេយ្យ របស់សហគមន៍នេសាទឱ្យបានត្រឹមត្រូវតាមប្រព័ន្ធការងារគណនេយ្យ
- រៀបចំគំរោងផែនការប្រើប្រាស់ហិរញ្ញវត្ថុរបស់សហគមន៍ ដើម្បីគណៈកម្មការសហគមន៍ពិនិត្យ និងសម្រេច
- ធ្វើរបាយការណ៍ និងរាយការណ៍ពីស្ថានភាពចំណូល-ចំណាយ ជូនគណៈកម្មការសហគន៍ជាទៀងរាល់ខែ
- ស្នើសុំការឯកភាពពីសមាជិកគណៈកម្មការសហគមន៍នេសាទ នូវរាល់ចំណាយផ្សេងៗ និងរក្សាទុកដាក់ឯកសារឱ្យបានត្រឹមត្រូវ
- រៀបចំបទ និងទទួលប្រាក់សមាជិកភាព និងភាគទានប្រចាំឆ្នាំពីសមាជិក ។

## ៥- ផ្នែកអប់រំ ផ្សព្វផ្សាយ

- អប់រំ ផ្សព្វផ្សាយពីខ្លឹមសារលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងសហគមន៍ ច្បាប់ អនុក្រឹត្យ សេចក្តីជូនដំណឹង និងលិខិត

  បទដ្ឋាននានា ដែលពាក់ព័ន្ធលើការគ្រប់គ្រងវិស័យជលផល បរិស្ថាន សិទ្ធិមនុស្ស អនាម័យ និងសុខភាព ។ល។ ជូនដល់សមាជិកសហគមន៍របស់ខ្លួន និងសហគមន៍នេសាទជិតខាង
- ស្វែងរកវិធីសាស្ត្រ និងបទពិសោធន៍ល្អៗ សម្រាប់ធ្វើការអប់រំ ផ្សព្វផ្សាយឱ្យរឹតតែមានប្រសិទ្ធភាព

- រៀបចំឯកសារ ផ្លាកសញ្ញា និងរូបភាពផ្សេងៗសម្រាប់ធ្វើការអប់រំ ផ្សព្វផ្សាយ
- រៀបចំវគ្គបណ្តុះបណ្តាល ទស្សនៈកិច្ចសិក្សា ដើម្បីលើកកំពស់ការយល់ដឹង និងផ្លាស់ប្តូរបទពិសោធន៍ក្នុងការគ្រប់គ្រងធនធានធម្មជាតិ
- ធ្វើរបាយការណ៍ពីលទ្ធផលលើការងារអប់រំ និងការវាយតំលៃផែនការអនុវត្ត ជូនប្រធានគណៈកម្មការសហគមន៍នេសាទជារៀងរាល់ខែ ។

## ៦_ ផ្នែកល្បាត

- ទទួលខុសត្រូវលើកិច្ចការការពារធនធានជលផល និងទប់ស្កាត់បទល្មើស ដែលកើតមានក្នុងដែននេសាទសហគមន៍
- ទទួលបន្ទុកពិនិត្យ តាមដាន ឃ្លាំមើល និងល្បាតនូវរាល់សកម្មភាពនេសាទ ។ ករណីចាំបាច់ត្រូវរាយការណ៍ព័ត៌មានជូនប្រធានឱ្យបានឆាប់រហ័ស ។
- សហការជាមួយសមត្ថកិច្ចជលផល បង្ក្រាបរាល់បទល្មើសជលផល នៅក្នុងកន្លែងនេសាទសហគមន៍ ។ ក្នុងករណីបន្ទាន់ និងចាំបាច់ ផ្នែកល្បាតសហគមន៍នេសាទអាចស្នើសុំអន្តរាគមន៍ពីសមត្ថកិច្ចនៅជិតខាង អាជ្ញាធរដែនដី ដើម្បីឃាត់ទុកវត្ថុតាងនៃបទល្មើស និងឃាត់ខ្លួនជនល្មើស រួចបញ្ជូនជាបន្ទាន់ទៅសមត្ថកិច្ចជលផល ដើម្បីធ្វើការដោះស្រាយបទល្មើសទៅតាមច្បាប់
- រៀបចំផែនការល្បាត និងចាត់វិធានការការពារធនធានធម្មជាតិក្នុងតំបន់គ្រប់គ្រង ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាព
- តាមដាន ស្រាវជ្រាវ និងគ្រប់គ្រងអ្នកមិនមែនជាសមាជិកសហគមន៍នេសាទ ដែលចូលរកនេសាទក្នុងកន្លែងនេសាទសហគមន៍
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលសកម្មភាពការងាររបស់ខ្លួន ជូនប្រធានគណៈកម្មការសហគមន៍នេសាទជារៀងរាល់ខែ ។

ធ្វើនៅភូមិល្បើត, ថ្ងៃទី..១៥.....ខែ..ធ្នូ.......ឆ្នាំ២០០៦..

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

សេង សុខុន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ៤_លក្ខន្តិកៈសហគមន៍នេសាទ

ឈ្មោះសហគមន៍នេសាទ : **ល្បៀត**

ភូមិ : ល្បៀត

ឃុំ : ជ្រោយបន្ទាយ

ស្រុក : ព្រែកប្រសព្វ

ខេត្ត : ក្រចេះ

## ជំពូកទី ១

## គោលបំណង និងនាមករណ៍

**ប្រការ ១.–**

លក្ខន្តិកៈនេះមានគោលបំណង៖

- កំណត់ក្របខ័ណ្ឌនៃការគ្រប់គ្រង ការការពារ ការអភិរក្ស ការអភិវឌ្ឍ ការប្រើប្រាស់ធនធានជលផលរបស់ សហគមន៍នេសាទប្រកបដោយនិរន្តរភាព
- ធ្វើជាគោលការណ៍គ្រឹះ និងជាយន្តការសម្រាប់ដំណើរការសហគមន៍នេសាទ
- ការពារសិទ្ធិ និងផលប្រយោជន៍របស់សមាជិកសហគមន៍នេសាទ និងផលប្រយោជន៍សាធារណៈ។

**ប្រការ ២.–**

ឈ្មោះសហគមន៍នេសាទ **ល្បៀត** ហៅកាត់ថា ស.ន.ល្ប. អាសយដ្ឋានភូមិ ល្បៀត ឃុំ ជ្រោយបន្ទាយ ស្រុក ព្រៃប្រសព្វ ខេត្ត ក្រចេះ។

សហគមន៍នេសាទនេះ មានការចូលរួមពីប្រជាពលរដ្ឋដែលរស់ក្នុង :

១. ភូមិ ល្បៀត ឃុំ ជ្រោយបន្ទាយ ស្រុក ព្រែកប្រសព្វ ខេត្ត ក្រចេះ។

**មានកម្មវត្ថុ**: ការពារ អភិរក្ស អភិវឌ្ឍន៍ និងគ្រប់គ្រងធនធានជលផលឱ្យមាននិរន្តរភាព។

## ជំពូកទី ២

## លក្ខខណ្ឌនៃការសុំចូលជាសមាជិក ភារកិច្ច និងសិទ្ធិរបស់សមាជិក

**ប្រការ ៣.–**

ប្រជាពលរដ្ឋទាំងពីរភេទ ដែលមានបំណងចង់ចូលជាសមាជិកសហគមន៍នេសាទ មានសិទ្ធិដាក់ពាក្យសុំចូលដោយស្ម័គ្រចិត្ត និងត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម ៖

-មានលំនៅដ្ឋាននៅក្នុងបណ្ដាភូមិនៃសហគមន៍នេសាទ

-មានសញ្ជាតិខ្មែរ

-មានអាយុចាប់ពី ១៨ឆ្នាំឡើង។

**ប្រការ ៤.-**

សមាជិកសហគមន៍នេសាទដែលបានបំពេញលក្ខខណ្ឌក្នុងប្រការ៣ ខាងលើមានសិទ្ធិ ៖

- ចូលរួមប្រជុំមហាសន្និបាត និងបោះឆ្នោតស្មើភាពគ្នា
- បោះឆ្នោត និងឈរឈ្មោះជាបេក្ខជននៃគណៈកម្មការសហគមន៍នេសាទស្របតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះ
- ទទួលព័ត៌មានអំពី ស្ថានភាពសេដ្ឋកិច្ចសង្គម របស់សហគមន៍នេសាទពីគណៈកម្មការសហគមន៍នេសាទ
- ស្នើឱ្យមានការកោះប្រជុំមហាសន្និបាតវិសាមញ្ញ ដើម្បីធ្វើការពិភាក្សា និងសម្រេចលើបញ្ហាណាមួយ បើមានការស្នើសុំពីសមាជិកយ៉ាងតិចមួយភាគបី (១/៣) នៃសមាជិកសហគមន៍នេសាទទាំងអស់
- ធ្វើនេសាទជាលក្ខណៈគ្រួសារស្របតាមច្បាប់ស្តីពី ជលផល កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធវិស័យជលផល
- ចូលរួមក្នុងសកម្មភាពទាំងអស់របស់សហគមន៍នេសាទ
- ប្តឹងតវ៉ា ឬផ្តល់ព័ត៌មានអំពីបាតុភាពទាំងឡាយ ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់សហគមន៍ទៅសមត្ថកិច្ចរដ្ឋបាលជលផល ក្រុមប្រឹក្សាឃុំ សង្កាត់ អាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធ
- ទទួលការគាំទ្រពីមជ្ឈដ្ឋាននានាដើម្បីផលប្រយោជន៍របស់សហគមន៍ ។

សមាជិកសហគមន៍នេសាទ ត្រូវទទួលខុសត្រូវរាល់សកម្មភាពរៀងៗខ្លួន និងរួមគ្នាចំពោះកំហុសដែលខ្លួនបានប្រព្រឹត្តក្នុងពេលបំពេញភារកិច្ច ដោយមិនទាន់គិតដល់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌឡើយ ។

សមាជិកសហគមន៍នេសាទចំនួនមួយភាគដប់(១/១០)ឡើងទៅអាចស្នើសុំឱ្យប្រធានគណៈកម្មការសហគមន៍នេសាទបញ្ចូលបញ្ហាមួយចំនួន ទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំ របស់គណៈកម្មការសហគមន៍នេសាទសាមី ហើយចំនួនសមាជិកសហគមន៍នេសាទដែលបានស្នើសុំខាងលើនេះ អាចចាត់តំណាងចំនួនបី (៣)នាក់ ចូលរួមប្រជុំដើម្បីចោទសួរគណៈកម្មការសហគមន៍នេសាទនូវបញ្ហាទាំងឡាយណា ដែលទាក់ទងនឹងចំណុចដែលបានស្នើឡើងនោះ ។

**ប្រការ ៥.-**

សមាជិកសហគមន៍នេសាទមានកាតព្វកិច្ច និងភារកិច្ចដូចខាងក្រោម ៖

- អនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីជលផល
- អនុវត្តតាមព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៤០ ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៥ ស្តីពីការបង្កើតសហគមន៍នេសាទ
- អនុវត្តតាមអនុក្រឹត្យលេខ ២៥ អនក្រ.បកចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ និងលិខិតបទដ្ឋានផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ
- អនុវត្តតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទ

សហគមន៍

- អនុវត្តតាមសេចក្តីសម្រេចរបស់មហាសន្និបាត និងគណៈកម្មការសហគមន៍នេសាទ
- បង់ប្រាក់សមាជិកភាពចំនួន **៥០០រៀល** ( ប្រាំរយរៀល) តាមការសម្រេចរបស់មហាសន្និបាត នៅពេលដែលដាក់ពាក្យសុំចូលជាសមាជិកសហគមន៍នេសាទ
- បង់ប្រាក់ភាគទានប្រចាំឆ្នាំចំនួន **៦.០០០រៀល** ( ប្រាំមួយពាន់រៀល) តាមការសម្រេចរបស់មហាសន្និបាត
- ចូលរួមក្នុងសកម្មភាពរបស់សហគមន៍នេសាទ ដើម្បីផលប្រយោជន៍ និងការរីកចំរើនរបស់សហគមន៍នេសាទ
- ចូលរួមការពារ ថែរក្សា និងគ្រប់គ្រងធនធានជលផលក្នុងសហគមន៍នេសាទ
- ចូលរួមឃ្លាំមើលទប់ស្កាត់ និងរាយការណ៍រាល់សកម្មភាពបទល្មើសជលផលក្នុងកន្លែងនេសាទសហគមន៍។

## ជំពូកទី ៣

## លក្ខណៈវិនិច្ឆ័យ លក្ខខណ្ឌនៃការលាឈប់ និងការបណ្តេញចេញពីសមាជិក

### ប្រការ ៦.~

សមាជិកសហគមន៍នេសាទមានសិទ្ធិលាឈប់ពីសមាជិកភាពបានដោយ ៖

- ដាក់ពាក្យសុំលាលែងជាលាយលក្ខណ៍អក្សរ
- ការផ្លាស់ប្តូរទីលំនៅចេញពីកន្លែងនេសាទសហគមន៍
- សាមីខ្លួនទទួលមរណភាព
- សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច ។

### ប្រការ ៧.~

សមាជិកសហគមន៍ អាចត្រូវបណ្តេញចេញពីសមាជិកភាពក្នុងលក្ខខណ្ឌដូចខាងក្រោម ៖

- ការមិនបង់ភាគទានចំនួន ៣ លើកជាប់ៗគ្នា
- ការធ្វើឱ្យប៉ះពាល់ខ្លាំងដល់ផលប្រយោជន៍នៃសហគមន៍នេសាទ ឬសមាជិកសហគមន៍នេសាទដទៃទៀត
- សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម
- សាមីខ្លួនបានប្រព្រឹត្តផ្ទុយនឹងលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះ។

## ជំពូកទី ៤
## របៀបរបបកាន់បញ្ជី និងឯកសារនានា

**ប្រការ ៨.-**

ប្រភពហិរញ្ញវត្ថុរបស់សហគមន៍នេសាទបានមកពី ៖

- ភាគទានរបស់សមាជិកសហគមន៍នេសាទ
- អំណោយពីសប្បុរសជន
- ជំនួយពីរាជរដ្ឋាភិបាល អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល
- ចំណូលស្របច្បាប់ផ្សេងៗទៀត។

**ប្រការ ៩.-**

រាល់ការចំណាយថវិកា សហគមន៍ត្រូវអនុវត្តដូចតទៅ៖

- ការចំណាយពី **១០០រៀល** (មួយរយរៀល) ដល់ **២០.០០០រៀល** (ពីរម៉ឺនរៀល) ត្រូវសម្រេចដោយប្រធានគណៈកម្មការសហគមន៍នេសាទ
- ការចំណាយពី **២០.១០០រៀល** (ពីរម៉ឺនមួយរយរៀល) ដល់ **១០០.០០០រៀល** (ដប់ម៉ឺនរៀល) ត្រូវសម្រេចដោយគណៈកម្មការសហគមន៍នេសាទ
- ការចំណាយពី **១០០.១០០រៀល** (ដប់ម៉ឺនមួយរយរៀល) ឡើងទៅត្រូវសម្រេចដោយមហាសន្និបាត។

**ប្រការ ១០.-**

សហគមន៍នេសាទត្រូវតម្កល់ទុកឯកសារ និងរៀបចំឱ្យមានបញ្ជី ៖

- ចំណូល ចំណាយថវិកា
- សារពើភ័ណ្ឌ
- សមាជិកសហគមន៍នេសាទ
- កំណត់ហេតុប្រជុំមហាសន្និបាតសហគមន៍នេសាទ
- កំណត់ហេតុប្រជុំគណៈកម្មការសហគមន៍នេសាទ
- ឯកសារដទៃទៀតដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ។

**ប្រការ ១១.-**

ការគ្រប់គ្រង និងប្រើប្រាស់ថវិកា ៖

- ការគ្រប់គ្រងថវិកា ត្រូវមានការកាន់បញ្ជីគណនេយ្យ
- ថវិកាចំណូលដែលទទួលបានពីប្រភពផ្សេងៗ ត្រូវរក្សាទុកក្នុងបេឡារបស់សហគមន៍នេសាទ

- រាល់ថវិកាចំណាយ ត្រូវមានរបាយការណ៍ទូទាត់ដោយមានសក្ខីបត្រ និងចុះបញ្ជីឱ្យបានត្រឹមត្រូវ
- ថវិកាដែលត្រូវចំណាយ គឺ សម្រាប់តែបម្រើឱ្យការងារគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍សហគមន៍នេសាទ។

## ជំពូកទី ៥
## គណៈកម្មការសហគមន៍នេសាទ

### ប្រការ ១២.-

សមាសភាពគណៈកម្មការសហគមន៍នេសាទរួមមាន ប្រធាន អនុប្រធាន និងសមាជិក។ គណៈកម្មការសហគមន៍នេសាទ ត្រូវបោះឆ្នោតជ្រើសរើសសមាជិកទទួលបន្ទុកលេខាធិការមួយរូប និងសមាជិកទទួលបន្ទុក ហិរញ្ញិកមួយរូប និងត្រូវពិភាក្សា បែងចែកភារកិច្ចសមាជិកផ្សេងទៀតតាមការជាក់ស្តែង។ ប្រធានគណៈកម្មការសហគមន៍នេសាទទទួលខុសត្រូវដឹកនាំ និងគ្រប់គ្រងសហគមន៍នេសាទទាំងមូល។ អនុប្រធាន គណៈកម្មការសហគមន៍នេសាទជាជំនួយការឱ្យប្រធាន ។

### ប្រការ ១៣.-

គណៈកម្មការសហគមន៍នេសាទមានអាណត្តិប្រាំ(៥)ឆ្នាំ ចាប់ពីថ្ងៃបោះឆ្នោត ហើយផុតកំណត់នៅពេលដែលមានគណៈកម្មការសហគមន៍នេសាទថ្មី ដែលត្រូវបានបោះឆ្នោតជ្រើសរើសក្នុងមហាសន្និបាតឱ្យចូលកាន់តំណែងជំនួស។ ក្នុងករណីសហគមន៍នេសាទដំណើរការមិនប្រក្រតី ដោយមូលហេតុដំណើរការមិនល្អ ឬអសមត្ថភាពក្នុង ការគ្រប់គ្រងសហគមន៍នេសាទ សមាជិកសហគមន៍នេសាទចំនួនមួយភាគបី (១/៣)មានសិទ្ធិស្នើសុំបើកមហាសន្និបាតវិសាមញ្ញ ដើម្បីបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទជាថ្មី។

### ប្រការ ១៤.-

ក្នុងករណីដែលសមាជិកគណៈកម្មការសហគមន៍នេសាទណាម្នាក់អវត្តមានដោយគ្មានមូលហេតុរយៈពេលប្រាំមួយ (៦)ខែ ឬសុំលាលែងមុនចប់អាណត្តិ បេក្ខជនដែលមានឈ្មោះតាមសំឡេងគាំទ្របន្ទាប់ ក្នុងពេលបោះឆ្នោតជ្រើសរើសក្នុងមហាសន្និបាតកន្លងមកត្រូវបានជ្រើសតាំងជំនួស ។

## ជំពូកទី ៦
## របៀបរបបប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ

### ប្រការ ១៥.-

គណៈកម្មការសហគមន៍នេសាទត្រូវកំណត់របបប្រជុំឱ្យបានទៀងទាត់រៀងរាល់ខែ។ កិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទអាចប្រព្រឹត្តទៅបាន លុះត្រាតែមានសមាជិកគណៈកម្មការចូលរួមយ៉ាងតិចចំនួន ២/៣ (ពីរភាគបី) នៃសមាជិករបស់គណៈកម្មការសហគមន៍នេសាទទាំងមូល។

**ប្រការ ១៦.-**

ប្រធានគណៈកម្មការសហគមន៍នេសាទ ជាអ្នកកោះអញ្ជើញ និងធ្វើជាប្រធានគ្រប់កិច្ចប្រជុំ ។ ក្នុងករណីប្រធានគណៈកម្មការសហគមន៍នេសាទអវត្តមាន អនុប្រធានដែលបានការប្រគល់សិទ្ធិត្រូវធ្វើជាប្រធានអង្គប្រជុំ។ រាល់ការប្រជុំត្រូវមានកំណត់ហេតុ និងបញ្ជីវត្តមានច្បាស់លាស់ ។

ប្រធានអង្គប្រជុំ ត្រូវធានាឱ្យគ្រប់កិច្ចប្រជុំសហគមន៍នេសាទប្រព្រឹត្តទៅដោយលក្ខណៈប្រជាធិបតេយ្យ មានរបៀបរៀបរយ និងគ្មានការរំខាន ។

ប្រធានអង្គប្រជុំ អាចបណ្តេញសមាជិកអង្គប្រជុំណាម្នាក់ចេញពីកិច្ចប្រជុំបាន ក្នុងករណីដែលសមាជិកនោះធ្វើឱ្យខូចសណ្តាប់ធ្នាប់អង្គប្រជុំ។

**ប្រការ ១៧.-**

ការសម្រេចលើបញ្ហាណាមួយ របស់សហគមន៍ដូចមានចែងខាងក្រោមនេះគឺ ត្រូវអនុម័តដោយកិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ ដោយមានសម្លេងគាំទ្រយ៉ាងតិចលើសពីពាក់កណ្តាល នៃចំនួនសមាជិកគណៈកម្មការសហគមន៍នេសាទ ដែលមានវត្តមានក្នុងអង្គប្រជុំ។ ក្នុងករណីដែលមានសម្លេងស្មើគ្នា មតិប្រធានអង្គប្រជុំជាឧត្តមានុភាព ៖

- សេចក្តីព្រាងកិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- សេចក្តីព្រាងគម្រោងថវិកា ចំណូល និងចំណាយក្នុងសហគមន៍នេសាទ
- ការព្យួរសមាជិកភាពរបស់សមាជិកដែលមានកំហុស
- ការទទួលពាក្យសុំចូលជាសមាជិកថ្មី
- ការដាក់ទណ្ឌកម្មតាមបទបញ្ជាផ្ទៃក្នុង ដល់សមាជិកសហគមន៍នេសាទ ។

បន្ទាប់ពីកិច្ចប្រជុំចប់ភ្លាម ប្រធានគណៈកម្មការសហគមន៍នេសាទ ត្រូវចាត់ឱ្យធ្វើការជូនដំណឹងដល់សមាជិកសហគមន៍នេសាទអំពីសេចក្តីសម្រេចរបស់ខ្លួន ។ សេចក្តីសម្រេចនៃអង្គប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការសហគមន៍នេសាទ ឬសាលាឃុំ សង្កាត់ ក្នុងរយៈពេល ៧ថ្ងៃយ៉ាងយូរ បន្ទាប់ពីការប្រជុំ។

## ជំពូកទី ៧

## មហាសន្និបាតសហគមន៍នេសាទ

**ប្រការ ១៨.-**

មហាសន្និបាតសហគមន៍នេសាទជាអង្គប្រជុំកំពូល ដើម្បីធ្វើការអនុម័ត និងធ្វើសេចក្តីសម្រេចចិត្តទាំងឡាយក្នុងនាមសហគមន៍នេសាទ ។ មហាសន្និបាតកំណើតដំបូង របស់សហគមន៍នេសាទ ត្រូវប្រារព្ធធ្វើឡើង បន្ទាប់ពីក្រុមស្ថាបនិកបានរៀបចំរួចរាល់នូវកិច្ចការទាំងឡាយដែលពាក់ព័ន្ធនឹងដំណើរការមហាសន្និបាត ។

ការកោះប្រជុំមហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទ ធ្វើឡើងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានការជួយសម្របសម្រួលពីសមត្ថកិច្ចរដ្ឋបាលជលផល តាមការស្នើសុំរបស់ក្រុមស្ថាបនិក ហើយត្រូវមានការចូលរួមពីសមាជិក ដែលបានដាក់ពាក្យស្នើសុំរួចមកហើយ ។

មហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទ អនុម័តនូវសេចក្តីសម្រេច និងកិច្ចការសំខាន់ដូចខាងក្រោម ៖

- អ្នកដែលដាក់ពាក្យសុំចូលជាសមាជិកសហគមន៍នេសាទ
- ឈ្មោះសហគមន៍នេសាទ
- លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ
- ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ។

**ប្រការ ១៩.-**

មហាសន្និបាតសាមញ្ញត្រូវរៀបចំឡើង ១ឆ្នាំម្តង ដើម្បីសរុបលទ្ធផលការងារប្រចាំឆ្នាំ និងអនុម័តនូវកិច្ចការសំខាន់ៗរបស់សហគមន៍នេសាទ។ ក្នុងករណីចាំបាច់សហគមន៍ អាចរៀបចំមហាសន្និបាតវិសាមញ្ញតាមការស្នើសុំពីសមាជិកសហគមន៍នេសាទចំនួនមួយភាគបី (១/៣) យ៉ាងតិច។

**ប្រការ ២០.-**

គណៈកម្មការសហគមន៍នេសាទ អាចអញ្ជើញរដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋាន ឬក្រុមប្រឹក្សាឃុំ សង្កាត់ សមត្ថកិច្ចពាក់ព័ន្ធ និងអ្នកគាំទ្រចូលរួមសង្កេតការណ៍ ឬសម្របសម្រួល ឬជាកិត្តិយសក្នុងមហាសន្និបាតសហគមន៍នេសាទ។

**ប្រការ ២១.-**

លក្ខខណ្ឌនៃដំណើរការមហាសន្និបាតមានដូចខាងក្រោម ៖

- ត្រូវធ្វើការផ្សព្វផ្សាយសេចក្តីជូនដំណឹងជាសាធារណៈ និងបិទប្រកាសនៅសាលាឃុំ សង្កាត់ និងទីស្នាក់ការសហគមន៍នេសាទ
- ការកោះអញ្ជើញសមាជិកសហគមន៍នេសាទឱ្យចូលរួមមហាសន្និបាតសាមញ្ញត្រូវធ្វើឡើងដប់(១០) ថ្ងៃយ៉ាងតិចមុនថ្ងៃបើកមហាសន្និបាត និងបី (៣) ថ្ងៃយ៉ាងតិចមុនថ្ងៃមហាសន្និបាតវិសាមញ្ញ
- មហាសន្និបាតសាមញ្ញ ឬ វិសាមញ្ញ អាចប្រជុំពិភាក្សាអនុម័ត និងសម្រេចបានលុះត្រាតែមានវត្តមានលើសពីពាក់កណ្តាលនៃចំនួនសមាជិកសហគមន៍នេសាទ
- អង្គប្រជុំមហាសន្និបាត ដឹកនាំដោយប្រធានគណៈកម្មការសហគមន៍នេសាទ ឬប្រធានអង្គប្រជុំដែលជ្រើសរើសដោយការអនុម័តក្នុងចំណោមសមាជិកវត្តមាន
- មហាសន្និបាតត្រូវអនុម័តលេខាកត់ត្រា ដើម្បីធ្វើកំណត់ហេតុ សេចក្តីសម្រេច និងបញ្ជីវត្តមាន
- លេខាកត់ត្រា និងប្រធានអង្គប្រជុំ ត្រូវចុះហត្ថលេខាលើកំណត់ហេតុ
- សមាជិកម្នាក់មានសំឡេងតែមួយគត់ ហើយមិនអាចបញ្ជូនមនុស្សមកតំណាងបានទេ
- សេចក្តីសម្រេចរបស់មហាសន្និបាត ត្រូវយកសំឡេងលើសពីពាក់កណ្តាលនៃចំនួនសមាជិកដែលមានវត្តមាន។

**ប្រការ ២២.-**

មហាសន្និបាតអនុម័ត ៖

- សេចក្តីសម្រេចដូចមានចែងក្នុងប្រការ ១៨ កថាខណ្ឌទី ៣ នៃលក្ខន្តិកៈនេះ
- កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ
- ការសុំលាលែង ឬការបណ្តេញចេញពីសមាជិកភាព ឬពីសមាជិកគណៈកម្មការសហគមន៍នេសាទ
- របាយការណ៍ប្រចាំឆ្នាំរបស់គណៈកម្មការសហគមន៍នេសាទ
- គម្រោងចំណូល ចំណាយរបស់សហគមន៍នេសាទ។

## ជំពូកទី ៨
## ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ

**ប្រការ ២៣.-**

ចំនួនសមាជិកគណៈកម្មការសហគមន៍នេសាទ និងចំនួនបេក្ខជនឈរឈ្មោះ ត្រូវអនុម័តដោយមហាសន្និបាត។

**ប្រការ ២៤.-**

កិច្ចដំណើរការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទគឺ ជាភារកិច្ចរបស់គណៈកម្មការរៀបចំការបោះឆ្នោតដែលអនុម័តដោយមហាសន្និបាត ។ គណៈកម្មការរៀបចំការបោះឆ្នោតមានសមាសភាពពីបី (៣) ទៅប្រាំ (៥) នាក់ ដែលមានប្រធាន អនុប្រធាន និងសមាជិកតាមការកំណត់ជាក់ស្តែង របស់មហាសន្និបាត

និងត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានចំណេះដឹង និងមានសីលធម៌ល្អ ។ គណៈកម្មការរៀបចំការបោះឆ្នោត ត្រូវធ្វើការប្តេជ្ញាចិត្តបង្ហាញពីភាពស្មោះត្រង់។

**ប្រការ ២៥.-**

គណៈកម្មការរៀបចំការបោះឆ្នោតមានភារកិច្ច ដូចខាងក្រោម ៖

- ប្រកាសបេក្ខជនឈរឈ្មោះ
- ណែនាំអំពីនីតិវិធីនៃការបោះឆ្នោត
- បង្ហាញរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ
- រាប់សន្លឹកឆ្នោត និងសរុបលទ្ធផលជូនគណៈអធិបតី ដើម្បីប្រកាសជូនមហាសន្និបាត

- ភារកិច្ចរបស់គណៈកម្មការរៀបចំការបោះឆ្នោតត្រូវបញ្ចប់ដោយស្វ័យប្រវត្តិ បន្ទាប់ពីការប្រកាសលទ្ធផលបោះឆ្នោតចប់ជាស្ថាពរ ។

**ប្រការ ២៦.-**

បេក្ខជនដែលទទួលបានសំឡេងឆ្នោតគាំទ្រច្រើនជាងគេបង្អស់គឺ ជាប្រធានគណៈកម្មការសហគមន៍នេសាទ ។ បេក្ខជនដែលទទួលបានសន្លឹកឆ្នោតបន្តបន្ទាប់ ត្រូវទទួលតួនាទីជាអនុប្រធាន ជាសមាជិកគណៈកម្មការសហគមន៍នេសាទ តាមលំដាប់លំដោយ ។ ក្នុងករណីបេក្ខជន ដែលមានសំឡេងគាំទ្រស្មើគ្នាត្រូវជ្រើសរើសស្ត្រី ឬបោះឆ្នោតរកអ្នកដែលមានសមត្ថភាព ដោយលើកដៃយកមតិលើសពីពាក់កណ្តាលនៃចំនួនសមាជិកសហគមន៍នេសាទដែលចូលរួម ។

## ជំពូកទី ៩

## លក្ខខណ្ឌនៃការរំសាយសហគមន៍នេសាទ និង នីតិវិធីដោះស្រាយវិវាទ

**ប្រការ ២៧.-**

ការរំសាយសហគមន៍នេសាទត្រូវផ្អែកតាម ៖

- សំណើរបស់ខណ្ឌរដ្ឋបាលជលផល នៅពេលដែលពិនិត្យឃើញថា មានការរំលោភធ្ងន់ធ្ងរលើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- សេចក្តីសម្រេចមហាសន្និបាត

ក្រោយពីរំសាយសហគមន៍នេសាទ ទ្រព្យសម្បត្តិរបស់សហគមន៍ត្រូវចាត់ចែងតាមការអនុម័តរបស់មហាសន្និបាត លើកលែងតែដែននេសាទដែលត្រូវប្រគល់ជូនរដ្ឋវិញ ។

**ប្រការ ២៨.-**

ក្នុងករណីមានការតវ៉ាចោទប្រកាន់ថា ដំណើរការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ មានភាពមិនប្រក្រតី អ្នកតវ៉ាត្រូវបង្ហាញភស្តុតាងឱ្យបានច្បាស់លាស់អំពី ភាពមិនប្រក្រតីនោះភ្លាម នៅមុនពេលប្រកាសលទ្ធផលបោះឆ្នោត ដើម្បីទុកលទ្ធភាពជូនមហាសន្និបាតពិនិត្យ និងសម្រេច ។

**ប្រការ ២៩.-**

វិវាទទាំងឡាយនៅក្នុងសហគមន៍នេសាទ ត្រូវដោះស្រាយដូចខាងក្រោម ៖

- គណៈកម្មការសហគមន៍នេសាទត្រូវសម្រុះសម្រួល និង ដោះស្រាយរាល់វិវាទ ដែលកើតមានឡើងនៅក្នុងសហគមន៍នេសាទរបស់ខ្លួន

- ក្នុងករណីគណៈកម្មការសហគមន៍នេសាទដោះស្រាយវិវាទនោះពុំបានសម្រេច ត្រូវបញ្ជូនសំណុំរឿងនោះទៅសមត្ថកិច្ចរដ្ឋបាលជលផល ដើម្បីដោះស្រាយទៅតាមបានានុក្រម ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធតាមការចាំបាច់។
- ក្នុងករណីបញ្ហាវិវាទនោះ នៅតែមិនអាចដោះស្រាយបាន គណៈកម្មការសហគមន៍នេសាទ និងរដ្ឋបាលជលផល ត្រូវបញ្ជូនសំណុំរឿងទៅតុលាការខេត្ត ក្រុងសាមី ដើម្បីដោះស្រាយតាមផ្លូវច្បាប់ ។

**ប្រការ ៣០.-**

សមាជិកសហគមន៍នេសាទរូបណា ដែលមិនគោរពតាមលក្ខន្តិកៈសហគមន៍នេសាទនេះ ត្រូវទទួលទណ្ឌកម្មពីគណៈកម្មការសហគមន៍នេសាទ ឬមហាសន្និបាតសហគមន៍នេសាទ ទៅតាមកម្រិតនៃទោសកំហុសរបស់ខ្លួន។

## ជំពូកទី ១០
## នីតិវិធីនៃការកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

**ប្រការ ៣១.-**

ការកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ ត្រូវសម្រេចដោយមហាសន្និបាត។ ការលើកសំណើកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទត្រូវធ្វើឡើង ដោយសមាជិកយ៉ាងតិចមួយភាគបី(១/៣) នៃសមាជិកសហគមន៍នេសាទទាំងអស់ ហើយសំណើនេះត្រូវដាក់ជូនគណៈកម្មការសហគមន៍នេសាទមួយខែមុន បើកមហាសន្និបាត។ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងនេះអាចកែប្រែបាន លុះត្រាតែមានសំឡេងយល់ព្រមលើសពីពាក់កណ្តាល នៃសមាជិកមហាសន្និបាតសហគមន៍នេសាទ។

## ជំពូកទី ១១
## អវសានប្បញ្ញត្តិ

**ប្រការ ៣២.-**

លក្ខន្តិកៈសហគមន៍នេសាទនេះ ត្រូវបានអនុម័តដោយមហាសន្និបាតរបស់សហគមន៍នេសាទលើកដំបូងនៅថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០០៩..... និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខារបស់ប្រធានគណៈកម្មការសហគមន៍នេសាទ។

ធ្វើនៅភូមិល្បៀត, ថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០០៩.....

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ៥_បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

ឈ្មោះសហគមន៍នេសាទ : **ល្បៀត**

ភូមិ : ល្បៀត

ឃុំ : ជ្រោយបន្ទាយ

ស្រុក : ព្រែកប្រសព្វ

ខេត្ត : ក្រចេះ

# បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

ដើម្បីធានាការគ្រប់គ្រងសហគមន៍នេសាទឱ្យប្រព្រឹត្តទៅមានប្រសិទ្ធភាព និងមានរបៀបរៀបរយល្អសហគមន៍នេសាទ **ល្បើត** សម្រេចដាក់ចេញនូវបទបញ្ជាផ្ទៃក្នុងដូចខាងក្រោម ៖

**ប្រការ ១.-**

គណៈកម្មការ និងសមាជិកសហគមន៍នេសាទគ្រប់រូប ត្រូវមានការស្មោះត្រង់ សាមគ្គីឯកភាពផ្ទៃក្នុងជួយស្ថាបនាព្រមទាំងចូលរួមរៀនសូត្របច្ចេកទេសផ្សេងៗ សម្រាប់បម្រើឱ្យការរីកចំរើនរបស់សហគមន៍នេសាទ ។

**ប្រការ ២.-**

គណៈកម្មការ សមាជិកសហគមន៍នេសាទ ឬបុគ្គលណាដែលបានកេងប្រវ័ញ្ចធ្វើឱ្យខូចខាត ឬបាត់បង់ទ្រព្យសម្បត្តិ និងផលប្រយោជន៍សហគមន៍នេសាទ ត្រូវទទួលទណ្ឌកម្មដូចខាងក្រោមនេះ ៖

- ចំពោះសមាជិកសហគមន៍នេសាទ ឬបុគ្គលដទៃទៀតត្រូវសង ឬទូទាត់ទៅតាមទំហំនៃការខូចខាតជាក់ស្តែងតាមការសម្រេចរបស់អង្គប្រជុំគណៈកម្មការសហគមន៍នេសាទ ។ ក្នុងករណីមិនព្រមសងត្រូវដាក់ជូនមហាសន្និបាតសម្រេច
- ចំពោះគណៈកម្មការសហគមន៍នេសាទត្រូវសង ឬទូទាត់សងការខូចខាតតាមការសម្រេចរបស់មហាសន្និបាត ។ ប្រសិនបើនីតិវិធីខាងលើនេះ នៅតែមិនអាចដោះស្រាយបានគឺ ត្រូវអនុវត្តតាមផ្លូវច្បាប់ និងបទបញ្ជាជាធរមាន ។

**ប្រការ ៣.-**

សមាជិកសហគមន៍នេសាទគ្រប់រូបត្រូវតែចូលរួមមហាសន្និបាត និងរាល់កិច្ចប្រជុំរបស់សហគមន៍នេសាទតាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មការសហគមន៍នេសាទ ។ក្នុងករណីដែលសមាជិកសហគមន៍ណាមិនបានមកចូលរួមប្រជុំចំនួនបី(៣)ដងជាប់គ្នាដោយគ្មានមូលហេតុច្បាស់លាស់ ត្រូវទទួលការណែនាំពីគណៈកម្មការសហគមន៍នេសាទ ។

ករណីនៅតែមិនរាងចាល គណៈកម្មការត្រូវធ្វើសំណើទៅមហាសន្និបាតសម្រេចដើម្បីបញ្ឈប់ពីសមាជិកភាព ។

**ប្រការ ៤.-** សិទ្ធិដាក់ទណ្ឌកម្ម ៖

**ក- គណៈកម្មការសហគមន៍នេសាទ**

- អប់រំណែនាំលើកទី១ លើកទី២ លើកទី៣
- ព្រមានផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ
- ព្យួរសមាជិកភាពរបស់សមាជិកសហគមន៍នេសាទ
- បញ្ជូនបញ្ហាទំនាស់ទៅមហាសន្និបាតសម្រេច
- ផ្អាកការនេសាទធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទ និងរាយការណ៍ជាបន្ទាន់ទៅសមត្ថកិច្ចរដ្ឋបាលជលផលចំពោះការនេសាទលើសទំហំ ចំនួន និងខុសប្រភេទ ពេលវេលា ទីតាំងតាមការកំណត់នៅក្នុងផែនការគ្រប់គ្រង និងកិច្ចព្រមព្រៀងនៅក្នុងកន្លែងនេសាទសហគមន៍ ។

**ខ- មហាសន្និបាត**

- អនុម័តការបណ្ដេញចេញដូចមានចែងក្នុងប្រការ ៧នៃលក្ខន្តិកៈសហគមន៍នេសាទ
- សម្រេចលើសំណងការខូចខាតលើទ្រព្យសម្បត្តិសហគមន៍នេសាទ
- សម្រេចដាក់ទណ្ឌកម្មដល់គណៈកម្មការ
- ដាក់ទណ្ឌកម្មដល់សមាជិក ឬបុគ្គលដទៃ ដែលគណៈកម្មការមិនអាចដោះស្រាយបាន ។

**ប្រការ ៥.-**

សមាជិកសហគមន៍នេសាទគ្រប់រូប ត្រូវរាយការណ៍ជូនគណៈកម្មការសហគមន៍នេសាទ អំពីសំភារៈឧបករណ៍នេសាទ ដែលគ្រួសារនីមួយៗ ប្រើប្រាស់នៅក្នុងកន្លែងនេសាទសហគមន៍ ។

**ប្រការ ៦.-**

សមាជិកសហគមន៍នេសាទអាចប្រើប្រាស់ឧបករណ៍នេសាទជាលក្ខណៈគ្រួសារក្នុងរដូវបើកនេសាទដូចមានចែងខាងក្រោម ៖

- មងប្រវែងមិនលើសពី ៣០០ ម៉ែត្រ ក្រឡា ២.៥ សង្ទីម៉ែត្រ ឡើង
- អួនបឹងប្រវែងមិនលើសពី ៣០ ម៉ែត ក្រឡា ៤ សង្ទីម៉ែត្រ ឡើង
- អួនទន្លេប្រវែងមិនលើសពី ១០០ ម៉ែត ក្រឡា ២,៥ សង្ទីម៉ែត្រ ឡើង
- ថ្នងទំហំមិនលើសពី ២ ម៉ែត្រ ក្រឡា ២ សង្ទីម៉ែត្រ ឡើង
- សំណាញ់ប្រវែងមិនលើសពី ៦ ម៉ែត្រ ក្រឡា ២ សង្ទីម៉ែត្រឡើង
- លាន់ចំនួនមិនលើសពី ៥០ គ្រឿង
- សន្ទូចរនងចំនួនមិនលើសពី ១០០ ផ្លែ
-សន្ទូចបង្កៃចំនួនមិនលើសពី ៤០ ផ្លែ
- សន្ទូចបបក់ចំនួន ០១ គ្រឿង
- អង្រុត ០១ គ្រឿង
- សៃយ៉ឺនមិនលើសពី ០២ គ្រឿង ក្រលាព្រួលធំជាង ១,៥ សង្ទីម៉ែត្រ
- ឡើមុខកាត់ ០,៤ ម៉ែត្រ ចំនួនមិនលើសពី ១០ គ្រឿង

*សំគាល់: ការប្រើប្រាស់ឧបករណ៍នេសាទនេះនឹងមានការកែប្រែបន្ទាប់ពីមានសេចក្ដីប្រកាសរបស់រដ្ឋមន្ត្រីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្ដីពីការប្រើប្រាស់ឧបករណ៍នេសាទជាលក្ខណៈគ្រួសារ ។*

**ហាមឃាត់ការប្រើប្រាស់ឧបករណ៍នេសាទមួយចំនួនដូចខាងក្រោម :**

-ឧបករណ៍ឆក់ និង ស្បៃមុងគ្រប់ប្រភេទ ។
- មងគ្រប់ប្រភេទដែលមានក្រឡាធំជាង ៨ សង់ទីម៉ែតឡើង

- ឧបករណ៍ឆក់ គ្រឿងផ្ទុះ និងសារធាតុពុលគ្រប់ប្រភេទ។
- ឧបករណ៍ បូម បាច ពង្រីងផ្ទៃកណាមួយនៃដែននេសាទ ដែលបង្កមហន្តរាយដល់ធនធានជលផល
- សម្រាស់ ឬ មធ្យោបាយផ្សេងទៀតដែលធ្វើឱ្យត្រី ឬ វារីសត្វគុំ។
- ច្បូក សាង ស្ន ឬ ឧបករណ៍បាញ់ព្រួញរួមផ្សំគ្រឿងផ្ទុះ។
- មងបោះ មងកាំង ឬ មងពស់ថ្នាន់គ្រប់ប្រភេទ។
- មង ឬអួនគ្រប់ប្រភេទ ដែលមានក្រឡាតូចជាងមួយសង្ទីម៉ែត្រកន្លះ (១.៥ ស.ម ) ក្នុងដែននេសាទសហគមន៍
- អួនអូសគ្រប់ប្រភេទនៅទឹកសាប និងឈិបយន្ត។
- ព្រួលគ្រប់ប្រភេទដែលមានចន្លោះពីត្រៀមមួយទៅត្រៀមមួយតូចជាងមួយសង្ទីម៉ែត្រកន្លះ (១.៥ស.ម)
- ខ្សែចងគ្រប់ប្រភេទ និងមធ្យោបាយផ្សេងៗទៀតដែលបង្កលក្ខណៈឱ្យត្រីផ្អើល។
- ទំនប់រួមផ្សំដោយឧបករណ៍នេសាទគ្រប់ប្រភេទ។
- ឧបករណ៍នេសាទទំនើប ឬឧបករណ៍នេសាទដែលបង្កើតថ្មី ឬ របៀបនេសាទបែបថ្មីដែលនាំមកនូវការបំផ្លាញមច្ឆជាតិ ធនធានជលផល ប្រព័ន្ធអេកូឡូស៊ីជលផល ឬ ដែលគ្មានកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ការផលិត ការទិញ ការលក់ ការដឹកជញ្ជូន ការរក្សាទុកឧបករណ៍ឆក់ ឧបករណ៍នេសាទស្បៃមុងគ្រប់ប្រភេទ អួនអូសគូ ឈិបយន្ត និងអួនអូសទឹកសាប ក្នុងបំណងធ្វើនេសាទ
- ការចាក់ចោល ការបោះចោល ការបង្ហូរ ឬ ការបាចពង្រាយទៅក្នុងដែននេសាទនូវកាកសំណល់រឹង ឬ រាវ ឬ សារធាតុពុលដែលបានកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនៃព្រះរាជាណាចក្រកម្ពុជា និងសន្ធិសញ្ញាអន្តរជាតិស្តីពីការបំពុលបរិស្ថាន ឬ ការប្រព្រឹត្តសកម្មភាពដែលធ្វើឱ្យពុល ឬ ការបង្កគ្រោះថ្នាក់ដល់វារីសត្វ និងវារីរុក្ខជាតិ
- ការធ្វើទំនប់កាត់ ឬ ការលុបទន្លេ ស្ទឹង ព្រែក អូរ បឹង ប្រឡាយ អាងទឹក និងអាងធម្មជាតិ ឬ ការជីកប្រឡាយរណ្តៅ និងស្រះទ្រង់ទ្រាយធំ ឬ ការសាងសង់សំណង់ថ្មីនានា ឬការបូមទឹកដែលអាចបង្កមហន្តរាយដល់ធនធានជលផលនៅក្នុងដែននេសាទ ត្រូវមានការសិក្សាវាយតម្លៃពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ការកាប់ ការឆ្ការ ការគាស់ ការរាន ការឈូសឆាយ ការដុត ឬ ការហ៊ុមព័ទ្ធកាន់កាប់ព្រៃលិចទឹក
- ការកាប់បំផ្លាញផ្តួលរំលំដើមឈើព្រៃលិចទឹក ឬ គាស់រំលើងប្រមូលគល់ឈើព្រៃលិចទឹក
- ការប្រមូល ដឹកជញ្ជូន និងការធ្វើសន្និធិឈើ អុស ធ្យូងប្រភេទឈើព្រៃលិចទឹកជាលក្ខណៈអាជីវកម្ម ឬពាណិជ្ជកម្ម
- ការសាងសង់ឡ រោងសិប្បកម្ម មូលដ្ឋានកែច្នៃ និងរោងចក្រគ្រប់ប្រភេទ ដែលប្រើប្រាស់វត្ថុធាតុដើមជាប្រភេទឈើព្រៃលិចទឹក។

**ប្រការ ៧.-**

សមាជិកសហគមន៍នេសាទដែល ៖

- ប្រព្រឹត្តផ្ទុយ ឬរារាំងមិនឱ្យសមាជិកដទៃអនុវត្តសិទ្ធិ និងកាតព្វកិច្ចដូចក្នុងប្រការ ៥ នៃលក្ខន្តិកៈត្រូវព្យួរសមាជិកភាពដោយគណៈកម្មការសហគមន៍នេសាទ ឬបណ្តេញចេញពីសមាជិកភាព ដោយមហាសន្និបាត
- មិនចូលរួមថែរក្សាការពារធនធានជលផល ឬមិនរាយការណ៍អំពី សកម្មភាពបទល្មើសជលផលត្រូវព្រមានដោយគណៈកម្មការសហគមន៍នេសាទ
- ប្រើប្រាស់ឧបករណ៍ហាមឃាត់ ធ្វើនេសាទខុសច្បាប់ កាប់ឆ្ការរានព្រៃលិចទឹកត្រូវទទួលការផ្តន្ទាទោសតាមច្បាប់ស្តីពីជលផល
- ធ្វើនេសាទក្នុងកន្លែងអភិរក្សរបស់សហគមន៍នេសាទត្រូវផ្អាកការនេសាទ ហើយធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទ និងរាយការណ៍ជាបន្ទាន់ទៅអាជ្ញាធរមូលដ្ឋាន និងរដ្ឋបាលជលផលមានសមត្ថកិច្ច
- អនុវត្តផ្ទុយនឹងបទប្បញ្ញត្តិច្បាប់ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កិច្ចព្រមព្រៀង ឬផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ត្រូវផ្អាកការនេសាទ ទទួលការព្រមានជាលាយលក្ខណ៍អក្សរធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទ និងរាយការណ៍ជាបន្ទាន់ ជូនទៅរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីដោះស្រាយតាមច្បាប់ ។

**ប្រការ ៨.-**

ចំពោះអ្នកប្រើប្រាស់ធនធានជលផល ដែលមិនមែនជាសមាជិកសហគមន៍នេសាទ អាចមានសិទ្ធិចេញចូល និងនេសាទក្នុងកន្លែងនេសាទសហគមន៍ ប៉ុន្តែត្រូវជូនព័ត៌មានដល់គណៈកម្មការសហគមន៍នេសាទ ហើយធ្វើកិច្ចសន្យា និងគោរពកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ និងបង់ភាគទានចំនួន **៤០.០០០រៀល** ( បួនម៉ឺនរៀល) ក្នុងមួយរដូវនេសាទសម្រាប់ការថែរក្សា ការពារធនធានជលផល ។

ក្នុងករណីដែលអ្នកប្រើប្រាស់ធនធានជលផល ដែលមិនមែនជាសមាជិកសហគមន៍នេសាទ មិនបានគោរពតាមប្រការនេះ គណៈកម្មការសហគមន៍នេសាទមានសិទ្ធិបញ្ឈប់សកម្មភាពនេសាទរបស់ជននោះ ហើយធ្វើការអប់រំណែនាំ ។

**ប្រការ ៩.-**

បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះ ត្រូវបានអនុម័តដោយមហាសន្និបាតរបស់សហគមន៍នេសាទលើកដំបូងនៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៧... និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខា ដោយប្រធានគណៈកម្មការសហគមន៍នេសាទ ។

ធ្វើនៅភូមិល្បៀត, ថ្ងៃទី ២៨.. ខែ កក្កដា ឆ្នាំ ២០០៧

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ៦_សេចក្តីថ្លែងការណ៍នៃការបង្កើតសហគមន៍នេសាទ

| | |
|---|---|
| ឈ្មោះសហគមន៍នេសាទ | : **ល្បៀត** |
| ភូមិ | : ល្បៀត |
| ឃុំ | : ជ្រោយបន្ទាយ |
| ស្រុក | : ព្រែកប្រសព្វ |
| ខេត្ត | : ក្រចេះ |

# សេចក្តីថ្លែងការណ៍

យើងខ្ញុំគណៈកម្មការសហគមន៍នេសាទ **ល្បៀត** ដែលបានបង្កើតនៅក្នុងឆ្នាំ ២០០២ ក្រោមការឧបត្ថម្ភ បច្ចេកទេស ដោយខណ្ឌរដ្ឋបាលជលផលក្រចេះក្នុងកិច្ចសហការជាមួយអង្គការ CAA ។

យើងខ្ញុំសូមជំរាបជូនលោកប្រធានខណ្ឌរដ្ឋបាលជលផលមេត្តាជ្រាបថា ការផ្តួចផ្តើមបង្កើតសហគមន៍នេសាទនេះ បានកើតឡើងក្រោយពីមានសំណូមពររបស់ប្រជាពលរដ្ឋ និងដោយមានគោលនយោបាយកែទម្រង់វិស័យជលផលរបស់រាជរដ្ឋាភិបាលនៅ ខែតុលា ឆ្នាំ ២០០០ មកធ្វើឱ្យប្រជាពលរដ្ឋភូមិល្បៀត ឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ បានព្រមព្រៀងគ្នាបង្កើតសហគមន៍នេសាទក្នុងគោលបំណងចូលរួមចំណែកគ្រប់គ្រង ការពារ ប្រើប្រាស់ និង អភិរក្សដែននេសាទសហគមន៍ឱ្យមាននិរន្តរភាព ។

ចាប់តាំងបង្កើតសហគមន៍នេសាទក្នុងឆ្នាំ ២០០២ រហូតមកដល់សព្វថ្ងៃ គឺយើងខ្ញុំបានខិតខំប្រឹងប្រែងធ្វើការងារសំខាន់ៗ និងសហការយាមល្បាត បង្ក្រាបបទល្មើសនេសាទ ទប់ស្កាត់ការពង្រីកដីកសិកម្ម បង្កើតកន្លែងអភិរក្សជលផល និង អភិវឌ្ឍន៍សហគមន៍នេសាទ ។ល ។

ទន្ទឹមនឹងនេះ សហគមន៍នេសាទយើងខ្ញុំបានរៀបចំរួចរាល់នូវឯកសារសម្រាប់ការបង្កើតកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ដូចដែលមានចែងក្នុងមាត្រា ៧ ជំពូកទី ២ នៃអនុក្រឹត្យ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទដែលរួមមានបញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង និងផែនទីកន្លែងនេសាទសហគមន៍ ។

ដោយផ្អែកលើសមិទ្ធិផលដូចបានរៀបរាប់ខាងលើ និងការសម្រេចរបស់មហាសន្និបាតដែលបានប្រារព្ធធ្វើនៅថ្ងៃទី ..២១..ខែ..វិច្ឆិកា..ឆ្នាំ ២០០២ យើងខ្ញុំគណៈកម្មការតំណាងឱ្យសហគមន៍នេសាទ **ល្បៀត** សូមគោរពជូននាយខណ្ឌរដ្ឋបាលជលផលក្រចេះ ស្នើចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ដែលមានភ្ជាប់មកជាមួយនូវ បញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ និងផែនទីកន្លែងនេសាទសហគមន៍ ដើម្បីពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ ។

យើងខ្ញុំគណៈកម្មការសហគមន៍នេសាទ **ល្បៀត** សូមធ្វើការប្តេជ្ញាចិត្ត និងសន្យាថានឹងដឹកនាំក្នុងការគ្រប់គ្រងសហគមន៍នេសាទ ដោយគោរពទៅតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ច្បាប់ជលផល និងលិខិតបទដ្ឋាននានា ដែលទាក់ទងនឹងវិស័យជលផល ។

យើងខ្ញុំសូមទទួលខុសត្រូវទាំងស្រុងចំពោះមុខ ច្បាប់នូវរាល់កំហុសឆ្គងនៃការអនុវត្តផ្ទុយពីបទបញ្ញត្តិទាំងឡាយដែលមានចែងក្នុងកិច្ចព្រមព្រៀង ។

អាស្រ័យហេតុដូចបានជំរាបជូនខាងលើសូមលោកនាយខណ្ឌរដ្ឋបាលជលផលក្រចេះមេត្តាពិនិត្យ និងសម្រេចដើម្បីចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ **ល្បៀត** ដោយអនុគ្រោះ ។

ធ្វើនៅភូមិល្បៀត ថ្ងៃទី២៧....ខែ.សីហា........ឆ្នាំ.២០០៧..

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

**សូមគោរពជូន**

**លោកនាយខណ្ឌរដ្ឋបាលជលផលក្រចេះ**

**កម្មវត្ថុ** : សំណើសុំចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ **ល្បៀត**។

**យោង** : - អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ លេខ ២៥ អនក្រ. បក ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ២០០៧។

- សេចក្តីសម្រេចរបស់មហាសន្និបាតសហគមន៍នេសាទ **ល្បៀត** ដែលបានប្រារព្ធធ្វើឡើងនៅថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០២ ។

**លិខិតភ្ជាប់** : កម្មវិធីចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ **ល្បៀត**។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកប្រធានមេត្តាជ្រាបថា សហគមន៍នេសាទ **ល្បៀត** បានបង្កើតឡើងនៅឆ្នាំ ២០០២ ដោយស្ម័គ្រចិត្ត និងមានគំនិតផ្តួចផ្តើមបង្កើនជីវភាពរស់នៅរបស់ប្រជាពលរដ្ឋភូមិខ្សាច់ទប់ ដោយមានការសម្របសម្រួលពីខណ្ឌរដ្ឋបាលជលផលក្រចេះ។សហគមន៍នេសាទមានទីតាំងស្ថិតនៅភូមិខ្សាច់ទប់ ឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះមាន ផ្ទៃទំហំ **១៩៨ ហិចតា** ដឹកនាំដោយគណៈកម្មការសហគមន៍នេសាទចំនួន **១១រូប** ស្រីចំនួន **៤រូប**មានសមាជិកសរុប ចំនួន **១៧៦រូប** ស្រីចំនួន **៦៩រូប** បន្ទាប់ពីបាន បង្កើតរួច មកសហគមន៍នេសាទ **ល្បៀត** បានដំណើរការយ៉ាងសស្រាក់សស្រាំដោយមានការចូលរួមឧបត្ថម្ភគាំទ្រពីនាយកដ្ឋាន អភិវឌ្ឍន៍សហគមន៍នេសាទនៃរដ្ឋបាលជលផល ស្ថាប័នជំនាញ ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងក្រុមប្រឹក្សាឃុំ។ ព្រមជាមួយនោះ គណៈកម្មការសហគមន៍នេសាទ បានរៀបចំ បញ្ជីឈ្មោះសមាជិក លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនទី និងកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍រួចជាស្រេច ហើយនឹងគ្រោងរៀបចំកម្មវិធីចុះ កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ជាមួយលោកនាយខណ្ឌរដ្ឋបាលជលផលក្រចេះដែលនឹងប្រព្រឹត្តធ្វើឡើងនាថ្ងៃទី២៨ខែសីហាឆ្នាំ ២០០៩. នៅភូមិល្បៀត ឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ដោយមានការចូលរួមពីសមាជិកសហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ស្ថាប័នពាក់ព័ន្ធ និងក្រុមប្រឹក្សាឃុំជាសាក្សី ។

សូមភ្ជាប់មកជាមួយនូវ :

១-កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍

២-ផែនទីកន្លែងនេសាទសហគមន៍មាត្រដ្ឋាន ១/៥០.០០០

៣-បញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ និងគណៈកម្មការសហគមន៍នេសាទ

៤-លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ

៥-សេចក្តីថ្លែងការ នៃការបង្កើតសហគមន៍នេសាទ ។

អាស្រ័យហេតុនេះ សូមលោកប្រធានមេត្តាពិនិត្យ និងសម្រេចដោយអនុគ្រោះ ។

ធ្វើនៅភូមិល្បៀត, ថ្ងៃទី ២៤.. ខែ.សីហា.... ឆ្នាំ ២០០១...

**ប្រធានគណៈកម្មការសហគមន៍នេសាទ ភូមិល្បៀត**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៣៣៛៣៣

# ៧_ឯកសារផ្សេងៗ

ឈ្មោះសហគមន៍នេសាទ : **ល្បៀត**

ភូមិ : ល្បៀត

ឃុំ : ជ្រោយបន្ទាយ

ស្រុក : ព្រែកប្រសព្វ

ខេត្ត : ក្រចេះ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៥៧៩ ប្រក.កសក

# ប្រកាស

## ស្តីពី

## ការចុះបញ្ជីសហគមន៍នេសាទខេត្តបន្ទាយមានជ័យ កំពង់ចាម ក្រចេះ ព្រះសីហនុ កណ្តាល កោះកុង តាកែវ ព្រៃវែង និង ខេត្តស្ទឹងត្រែង

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នសរកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៤០ ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៥ ស្តីពីការបង្កើតសហគមន៍នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និង កែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និង ការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១២៣ អនក្រ.បក ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៩ ស្តីពីការកំណត់ប្រភេទផលផលិតផលជលផលដែលកំពុងរងគ្រោះថ្នាក់
- បានឃើញអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ
- បានឃើញប្រកាសលេខ ៣១៦ ប្រក.កសក ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៧ ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ
- យោងតាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា ប្រធានរដ្ឋបាលជលផល

ស្នាក់ការលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០

# សម្រេច

**ប្រការ ១.-**

ត្រូវបានចុះបញ្ជីជាផ្លូវការ និង ទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ នូវសហគមន៍នេសាទចំនួន ៦៣ ក្នុងខេត្តបន្ទាយមានជ័យ កំពង់ចាម ក្រចេះ ព្រះសីហនុ កណ្ដាល កោះកុង តាកែវ ព្រៃវែង និង ខេត្តស្ទឹងត្រែង ដែលមានឈ្មោះសហគមន៍នេសាទ ទំហំកន្លែងនេសាទសហគមន៍ និយាមកាជាចំណុចគោលនៃព្រំប្រទល់កន្លែងនេសាទសហគមន៍ ចំនួនភូមិ និង ទីតាំងភូមិសាស្ត្រ ដូចមាននៅក្នុងតារាង និង ផែនទីកន្លែងនេសាទសហគមន៍នីមួយៗ ជាឧបសម្ព័ន្ធភ្ជាប់ប្រកាសនេះ ។

**ប្រការ ២.-**

ព្រំប្រទល់កន្លែងនេសាទសហគមន៍នីមួយៗ ដែលបានកំណត់ក្នុងផែនទី ដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវបានទទួលស្គាល់ដោយនាយខណ្ឌរដ្ឋបាលជលផល អាជ្ញាធរដែនដី ប្រធានរដ្ឋបាលជលផល និង រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

**ប្រការ ៣.-**

ទំហំកន្លែងនេសាទសហគមន៍ និយាមកាជាចំណុចគោលនៃព្រំប្រទល់កន្លែងនេសាទសហគមន៍ ចំនួនភូមិ និង ទីតាំងភូមិសាស្ត្ររបស់សហគមន៍ ដូចមានចែងក្នុងប្រការ ១ អាចកែប្រែបានតាមការចាំបាច់ ។

**ប្រការ ៤.-**

ប្រកាស ឬសេចក្ដីសម្រេចទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥.-**

អគ្គលេខាធិការ អគ្គាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធានរដ្ឋបាលជលផល ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានផែនការ ស្ថិតិ ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ប្រធានមន្ទីរកសិកម្មខេត្តពាក់ព័ន្ធ និង ប្រធានសហគមន៍នេសាទ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១០

រដ្ឋមន្ត្រី

ច័ន្ទ.សារុន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- សាលាខេត្តពាក់ព័ន្ធ
- ដូចប្រការ ៥
- ឯកសារ.កាលប្បវត្តិ

**ឧបសម្ព័ន្ធ:**ភ្ជាប់ប្រកាសលេខ....៥៧៩ ប្រក.កសក.ចុះថ្ងៃទី១០........ខែ...កញ្ញា.........ឆ្នាំ ២០១០

# សហគមន៍នេសាទក្នុងខេត្តបន្ទាយមានជ័យ កំពង់ចាម ក្រចេះ ព្រះសីហនុ កណ្តាល កោះកុង តាកែវ ព្រៃវែង និង ខេត្តស្ទឹងត្រែង ត្រូវបានចុះបញ្ជីនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

| ល.រ | ឈ្មោះសហគមន៍នេសាទ | ផ្ទៃដី (ហិកតា) | Projection :UTM, Everest 1830, Datum : Indian 1960, Zone : 48 N | | ចំនួនភូមិ | ទីតាំងភូមិសាស្ត្រ | |
|---|---|---|---|---|---|---|---|
| | | | (X,Y) | (X,Y) | | ឃុំ/សង្កាត់ | ស្រុក/ក្រុង |
| **១.ខេត្តបន្ទាយមានជ័យ** | | | | | | | |
| ១ | រហាលលិចស្រះ | ២.១៦៤ | A. (302732, 1502321)<br>B. (302012, 1500312)<br>C. (301685, 1497986) | D. (300093, 1497320)<br>E.( 298482, 1499065)<br>F.(299607, 1504511) | ៥ | ព្រះនេត្រព្រះ | ព្រះនេត្រព្រះ |
| ២ | រុងរឿង | ៣.១៩៥ | A. (296237, 1494743)<br>B. (299491, 1489122)<br>C. (302933, 1490464) | D. (304163, 1493000)<br>E. (302381, 1494321)<br>F. (300710, 1496417) | ៣ | គោកបល្ល័ង្គ តាឡំ និង ព្រះនេត្រព្រះ | ព្រះនេត្រព្រះ និង មង្គលបុរី |
| ៣ | គយម៉ែង ព្រះនេត្រព្រះ | ១.៣៧៦ | A. (294778, 1500557)<br>B. (294883, 1499035)<br>C. (295866, 1497219) | D. (297820, 1497889)<br>E. (297966, 1498964)<br>F. (296876, 1502142) | ២ | គយម៉ែង និង ព្រះនេត្រព្រះ | ព្រះនេត្រព្រះ និង មង្គលបុរី |
| ៤ | តាឡំ ព្រះនេត្រព្រះ | ១.២២៨ | A. (295866, 1497219)<br>B. (300710, 1496417)<br>C. (300093, 1497320) | D. (299621, 1497838)<br>E. (297966, 1498964)<br>F. (297753, 1497434) | ៣ | តាឡំ និង ព្រះនេត្រព្រះ | ព្រះនេត្រព្រះ និងមង្គលបុរី |
| ៥ | ភ្លៀត កោះពងសត្វ | ៤.៨៦៧ | A. (291817, 1500732)<br>B. (292739, 1499491)<br>C. (283690, 1503588) | D. (283779, 1503525)<br>E. (292811, 1505126)<br>F. (2909, 1505126) | ១១ | ភ្លៀត និង កោះពងសត្វ | សិរីសោភ័ណ |
| **២.ខេត្តកំពង់ចាម** | | | | | | | |
| ១ | បារ៉ាយរុងរឿង | ២.៤៩៩ | A. (586250, 1342162)<br>B. (586426, 1349159)<br>C. (588998, 1347103) | D. (591017, 1347674)<br>E. (589732, 1350707)<br>F. (586620, 1348365) | ៣ | ឈូក | ក្រូចឆ្មារ |
| ២ | ថែរក្សាការពារមច្ឆាដងស្ទឹង | ២.៨៦៧ | A. (580844, 1344050)<br>B. (584793, 1342151)<br>C. (586620, 1348365) | D. (585884, 1336355)<br>E. (586222, 1336240)<br>F. (581761, 1345986) | ៣ | ឈូក | ក្រូចឆ្មារ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣ | ២៩ វិច្ឆិកា | ១.៣៥៦ | A. (577892, 1353425)<br>B. (577486, 1349562)<br>C. (578389, 1348826) | D.(579712, 1348632)<br>E. (580441, 1348733)<br>F. (580966, 1353191) | ៤ | ប៉ឺស ១ | ក្រូចឆ្មារ |
| ៤ | សាមគ្គីមាត់ឃ្មង់ | ២.៧៦៥ | A. (551722, 1318516)<br>B. (558282, 1320620)<br>C. (560810, 1321168) | D.(557726, 1324617)<br>E. (555439, 1319468)<br>F. (558530, 1323521) | ៨ | ទន្លេបិទ និង ជីរោទិ៍២ | ត្បូងឃ្មុំ |
| ៥ | បឹងកក់ | ១៦៥ | A. (533837, 1312006)<br>B. (533927, 1313825) | C.(532345, 1312342)<br>D.(532851, 1311851) | ២ | ព្រែកតានង់ | កោះសូទិន |
| ៦ | បឹងវាម | ៦៨២ | A. (518026, 1305520)<br>B. (518830, 1306085)<br>C. (519775, 1308861) | D.(518663, 1309214)<br>E.(517641, 1308590)<br>F.(517253, 1307656) | ៣ | ប្រាំយ៉ាម | ស្រីសន្ធរ |
| ៧ | បឹងថ្លាស់ | ៣០៩ | A. (494023, 1320038)<br>B. (492695. 1320105)<br>C. (491626, 1320048) | D.(490203, 1319362)<br>E.(490990, 1319226)<br>F.(492249, 1319017) | ៣ | បាធាយ និងជាលា | បាធាយ |
| ៨ | ប្រាំងខ្ពុម | ២.២៩១ | A. (499088, 1313600)<br>B. (496355, 1312480)<br>C. (496355, 1314620) | D.(497866, 1317547)<br>E.(498842, 1321898)<br>F.(499948, 1317424) | ១០ | ច្បារអំពៅ តាំងក្រាំង ជាលា និងព្រែកកុយ | បាធាយ និង កងមាស |
| ៩ | សាមគ្គីឃុំមៀន | ២៩៣ | A. (536536, 1327825)<br>B. (536197, 1328679)<br>C. (535237, 1327335) | D.(534355, 1327045)<br>E.(532834, 1326647)<br>F.(533105, 1327327) | ៩ | ឃុំមៀន | ព្រៃឈរ |
| ១០ | អាងទឹកថ្មជាទឹកឆា | ៨៥,៨៥ | A. (521377, 1346985)<br>B. (520833, 1344133)<br>C. (521434, 1347045 ) | D.(521568, 1347651)<br>E.(521723, 1347128)<br>F.(521681, 1346847) | ៤ | បឹងណាយ និង ក្រូច | ព្រៃឈរ |
| ១១ | អាងទឹកកែប្រែ | ២៦៧ | A. (547218, 1341957)<br>B. (546599, 1341901)<br>C. (545477, 1342334) | D.(545641, 1343199)<br>E.(545900, 1343702)<br>F.(547026, 1342655) | ៣ | ស្រក | កំពង់សៀម |
| ១២ | អាងទឹកជ្រោយចេក | ១៩៣ | A. (547968, 1339471)<br>B. (547403, 1339372)<br>C. (547042, 1336723) | D.(546532, 1336918)<br>E.(546569, 1337474)<br>F.(547495, 1338674) | ៨ | ទ្រាន | កំពង់សៀម |
| **៣.ខេត្តក្រចេះ** | | | | | | | |
| ១ | កំពង់គរ | ១.៨៥៦ | A. (609772, 1357952)<br>B. (606391, 1360532)<br>C. (602805, 1359585) | D.(601721, 1357540)<br>E.(602157, 1359417)<br>F.(602161, 1359425) | ៤ | កំពង់គរ | ព្រែកប្រសព្វ |
| ២ | កែងកំពង់ដរ | ៤៤០ | A. (606800, 1383587)<br>B. (605456, 1385375)<br>C. (605791, 1386792) | D.(605878, 1387785)<br>E.(607757, 1386789)<br>F.(607767, 1386797) | ២ | ជ្រោយបន្ទាយ | ព្រែកប្រសព្វ |



៤

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣ | ខ្សាច់ទប់ | ៣០៧ | A. (608410, 1388476)<br>B. (607596, 1388909)<br>C. (607587, 1390980) | D.(609076, 1390328)<br>E.(608392, 1388466)<br>F.(608395, 1388467) | ១ | ជ្រោយបន្ទាយ | ព្រែកប្រសព្វ |
| ៤ | ពៀត | ១៩៨ | A. (609488, 1391809)<br>B. (608670, 1391989)<br>C. (607876, 1391873) | D.(607820, 1391730)<br>E.(609289, 1391045)<br>F.(608089, 1390633) | ១ | ជ្រោយបន្ទាយ | ព្រែកប្រសព្វ |
| ៥ | អូរលុង | ៣.៨៧២ | A. (612116, 1366416)<br>B. (610833, 1366083)<br>C. (609200, 1362916) | D.(609041, 1362166)<br>E.(608073, 1362166)<br>F.(610604, 1358541) | ៤ | ព្រែកប្រសព្វ | ព្រែកប្រសព្វ |
| ៦ | ហាន់ជ័យ | ១.៧២០ | A. (604495, 1354705)<br>B. (604360, 1351379)<br>C. (602575, 1349976) | D.(601828, 1349986)<br>E.(601456, 1350971)<br>F.(600365, 1351940) | ៤ | ហាន់ជ័យ | ឆ្លូង |
| ៧ | កញ្ជរ | ១.៩០០ | A. (612189, 1363553)<br>B. (614176, 1364149)<br>C. (615446, 1362808) | D.(616702, 1365957)<br>E.(616100, 1361382)<br>F.(612138, 1361255) | ៤ | កញ្ជរ | ឆ្លូង |
| ៨ | ស្រែស្តៅ | ៦៦៥ | A. (614845, 1380072)<br>B. (614702, 1379433)<br>C. (613752, 1379242) | D.(611818, 1379003)<br>E.(611821, 1379008)<br>F.(611826, 1379012) | ៥ | អូរឬស្សី | ក្រចេះ |
| ៩ | រកាកណ្តាល | ២.៣៥៣ | A. (610690, 1379050)<br>B. (613200, 1379020)<br>C. (616915, 1378447) | D.(616932, 1377012)<br>E.(616800, 1373800)<br>F.(611637, 1375267) | ២ | រកាកណ្តាល | ក្រចេះ |
| ១០ | ព្រែកតាអាំ | ១.២១៧ | A. (615019, 1363834)<br>B. (618036, 1365734)<br>C. (618822, 1368935) | D.(618825, 1368938)<br>E.(618838, 1368944)<br>F.(618846, 1368949) | ១ | បុសលាវ | ចិត្របុរី |
| ១១ | ព្រែកតាចឹង | ៥៣០ | A. (614390, 1370195)<br>B. (615608, 1368967)<br>C. (617438, 1369827) | D.(617458, 1371399)<br>E.(615642, 1370787)<br>F.(615653, 1370701) | ១ | បុសលាវ | ចិត្របុរី |
| ១២ | កាំពី | ១១៥ | A. (611740, 1392795)<br>B. (612556, 1393665)<br>C. (612018, 1394092) | D.(611422, 1394577)<br>E.(611429, 1394583)<br>F.(611441, 1394507) | ១ | សំបុក | ចិត្របុរី |
| **៤.ខេត្តព្រះសីហនុ** | | | | | | | |
| ១ | ជ្រលង | ១.៥៧២ | A. (380076, 1182216)<br>B. (379845, 1181762)<br>C. (379372, 1181722) | D.(375704, 1177531)<br>E.(376757, 1184014)<br>F.(378385, 1184859) | ២ | ទឹកល្អក់ | ព្រៃនប់ |
| ២ | បឹងរាំង | ៤.១២៥ | A. (378385, 1184859)<br>B. (376757, 1184014) | C.(370975, 1193535)<br>D.(377998, 1191996) | ២ | សាមគ្គី | ព្រៃនប់ |
| ៣ | ចុងអូរ | ២.៦២៩ | A. (355704, 1177351)<br>B. (374869, 1177892)<br>C. (369408, 1180302) | D.(370769, 1182787)<br>E.(375769, 1184018)<br>F.(376620, 1183853) | ១ | សំរុង | ព្រៃនប់ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៤ | បន្ទាយប្រិយ | ២.២២៩ | A. (369408, 1180302)<br>B. (374869, 1177892)<br>C. (367322, 1177261) | D.(372511, 1176306)<br>E.(372430, 1175949)<br>F.(375813, 1175066) | ១ | អណ្តូងថ្ម | ព្រៃនប់ |
| ៥ | ជំពូខ្មៅ | ២.៦៧០ | A. (367922, 1177261)<br>B. (372430, 1175949)<br>C. (376725, 1176293) | D.(378330, 1171251)<br>E.(374643, 1173255)<br>F.(373186, 1173965) | ១ | ទួលទទឹង | ព្រៃនប់ |
| ៦ | បែកក្រង់ | ៣.៤៣១ | A. (367545, 1175720)<br>B. (373142, 1170860)<br>C. (374643, 1173255) | D.(372080, 1174347)<br>E.(378330, 1171251)<br>F.(375026, 1172940 | ១ | ព្រៃនប់ | ព្រៃនប់ |
| ៧ | បិតត្រាំង | ២.០២០ | A. (350555, 1169565)<br>B. (346115, 1167440)<br>C. (343518, 1161599) | D.(343011, 1166924)<br>E.(355443, 1167275)<br>F.(349834, 1171862) | ១ | បិតត្រាំង | ព្រៃនប់ |
| ៨ | អូរត្រេះ | ៤៩៦ | A. (349350, 1186552)<br>B. (349206, 1184497)<br>C. (349902, 1186907) | D.(348928, 1185105)<br>E.(351604, 1184232)<br>F.(351295, 1185570) | ៣ | អូរត្រេះ | ស្ទឹងហាវ |
| ៩ | ទំនប់រលក | ១.១៨៩ | A. (350446, 1190329)<br>B. (349883, 1188002)<br>C. (352935, 1187700) | D.(357250, 1185122)<br>E.(355535, 1187813) | ៤ | ទំនប់រលក | ស្ទឹងហាវ |
| ១០ | កំពេញ | ៣.៤២៧ | A. (349883, 1188002)<br>B. (349635, 1188638)<br>C. (349175, 1188189) | D.(349350, 1186552)<br>E.(349180, 1186589)<br>F.(348001, 1187475) | ២ | កំពេញ | ស្ទឹងហាវ |
| ១១ | ភូមិព្រែកស្វាយ | ៧.៤៤៧ | A. (307995, 1194748)<br>B. (300031, 1191992)<br>C. (316003, 1190363) | D.(300485, 1185146)<br>E.(303955, 1185165)<br>F.(309090, 1186759) | ១ | កោះរ៉ុង | ព្រះសីហនុ |
| ១២ | ភូមិកោះរ៉ុងសន្លឹម | ១១.២៥៧ | A. (318101, 1182652)<br>B. (311097, 1172864)<br>C. (312892, 1168053 ) | D.(314587, 1165990)<br>E.(315796, 1164583)<br>F.(320403, 1170511) | ២ | កោះរ៉ុង | ព្រះសីហនុ |
| **៥.ខេត្តកណ្តាល** | | | | | | | |
| ១ | អាងទឹកបឹងជន្លេន | ៦០ | A. (499744, 1300489)<br>B. (500377, 1300897)<br>C. (500528, 1301273) | D.(500740, 1301435)<br>E.(500625, 1301753)<br>F.(500298, 1301557) | ៤ | ឫស្សីជ្រោយ | មុខកំពូល |
| ២ | បឹងដំរីស្លូង និងកាហយ | ៣៧ | A. (500233, 1301602)<br>B. (499302, 1299042)<br>C. (498166, 1298826) | D.(497422, 1297556)<br>E.(497512, 1297249)<br>F.(497425, 1297530) | ៣ | ព្រែកអញ្ចាញ | មុខកំពូល |
| **៦.ខេត្តកោះកុង** | | | | | | | |
| ១ | ឃុំព្រែកខ្សាច់ | ៩.៧៣៨ | A. (293668, 1247244)<br>B. (288424, 1247998)<br>C. (288887, 1237150) | D.(284170, 1240138)<br>E.(294238, 1252292)<br>F.(295252, 1250201) | ៣ | ព្រែកខ្សាច់ | គិរីសាគរ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **៧.ខេត្តតាកែវ** | | | | | | | |
| ១ | ពត់សរ | ១.២២២ | A. (490743, 1247115)<br>B. (490376, 1249451)<br>C. (488696, 1254107) | D.(488152, 1254148)<br>E.(491770, 1252469)<br>F.(491452, 1247771) | ១១ | ពត់សរ | បាទី |
| ២ | ចំប៉ី | ៤៦១ | A. (489101, 1247711)<br>B. (489635, 1249122)<br>C. (490305, 1246608) | D.(488719, 1244541)<br>E.(490005, 1246668)<br>F.(489602, 1248426) | ៥ | ចំប៉ី | បាទី |
| **៨.ខេត្តព្រៃវែង** | | | | | | | |
| ១ | ភូមិខ្សាច់ | ៣.១៣៣ | A. (527591, 1213893)<br>B. (532200, 1210384)<br>C. (528290, 1207425) | D.(527427, 1208486)<br>E.(527606, 1211826)<br>F.(526639, 1213387) | ៥ | កោះសំពៅ | ពាមជរ |
| ២ | បីឃុំ | ៤.៥១៨ | A. (538194, 1261436)<br>B. (536360, 1256535)<br>C. (533604, 1253696) | D.(533871, 1254132)<br>E.(532305, 1258669)<br>F.(532649, 1259999) | ៥ | កំពង់ប្រាសាទ | ពាមជរ |
| **៩.ខេត្តស្ទឹងត្រែង** | | | | | | | |
| ១ | ភូមិអូរគ្រែល | ១៧០ | A. (603618, 1497865)<br>B. (604042, 1497357)<br>C. (601350, 1494952) | D.(601274, 1495788)<br>E.(600976, 1498675)<br>F.(601026, 1498589) | ១ | ថាឡាបរីវ៉ាត់ | ថាឡាបរីវ៉ាត់ |
| ២ | ភូមិវាលខ្សាច់ | ៣៨០ | A. (603618, 1497865)<br>B. (604042, 1497357)<br>C. (608554, 1501440) | D.(608550, 1509029)<br>E.(608510, 1504570)<br>F.(608217, 1505143) | ១ | ថាឡាបរីវ៉ាត់ | ថាឡាបរីវ៉ាត់ |
| ៣ | ភូមិពងទឹក | ១៨១ | A. (596811, 1486694)<br>B. (596616, 1487067)<br>C. (596226, 1487067) | D.(596823, 1488663 )<br>E.(596771, 1488856)<br>F.(597135, 1489645) | ១ | អូររ៉ៃ | ថាឡាបរីវ៉ាត់ |
| ៤ | ភូមិអូររ៉ៃ | ២.៥៦៤ | A. (597325, 1490015)<br>B. (597511, 1489887)<br>C. (599385, 1492320) | D.(594204, 1495132)<br>E.(592684, 1491304)<br>F.(594308, 1490115 | ១ | អូររ៉ៃ | ថាឡាបរីវ៉ាត់ |
| ៥ | ភូមិអន្លង់ស្វាយ | ២៨០ | A. (601390, 1494824)<br>B. (600915, 1495161)<br>C. (600714, 1494853) | D.(600083, 1493844)<br>E.(599787, 1493344)<br>F.(599072, 1492432) | ១ | អូររ៉ៃ | ថាឡាបរីវ៉ាត់ |
| ៦ | ភូមិកាំងចាម | ២០៧ | A. (593881, 1481454)<br>B. (593683, 1481485)<br>C. (593919, 1482157) | D.(596118, 1484837)<br>E.(596341, 1485235)<br>F.(596493, 1485955) | ១ | កាំងចាម | ថាឡាបរីវ៉ាត់ |

| | | | | | | |
|---|---|---|---|---|---|---|
| ៧ | ភូមិកាំងក្រោក | ២១៧ | A. (600066, 1475463)<br>B. (599887, 1475216)<br>C. (597709, 1476454) | D.(596731, 1476665)<br>E.(595683, 1477299)<br>F.(594855, 1477437) | ១ | កាំងចាម | ថាឡាបរិវ៉ាត់ |
| ៨ | ភូមិកាំងដែក | ៩៧៣ | A. (599373, 1491075)<br>B. (599255, 1491970)<br>C. (595639, 1483807) | D.(594701, 1477934)<br>E.(595568, 1477883)<br>F.(595786, 1483308) | ១ | កោះស្រឡាយ | ថាឡាបរិវ៉ាត់ |
| ៩ | ភូមិស្មាកោះ | ៤០៣ | A. (599809, 1488872)<br>B. (601219, 1489325)<br>C. (600347, 1492376) | D.(599255, 1492075)<br>E.(599373, 1491970)<br>F.(599636, 1492247) | ១ | កោះស្រឡាយ | ថាឡាបរិវ៉ាត់ |
| ១០ | ភូមិស្ដៅ១ | ១.៩៧១ | A. (619512, 1504855)<br>B. (628224, 1517651)<br>C. (630527, 1519556) | D.(636444, 1522894)<br>E.(635260, 1527562)<br>F.(635087, 1528002) | ១ | ស្ដៅ | សេសាន |
| ១១ | ភូមិស្ដៅ២ | ៣២៤ | A. (619512, 1504855)<br>B. (619189, 1505143)<br>C. (618584, 1504464) | D.(616420, 1501279)<br>E.(616798, 1501006)<br>F.(617379, 1502221) | ១ | ស្ដៅ | សេសាន |
| ១២ | ភូមិលើ | ១១៨ | A. (603555, 1537758)<br>B. (604230, 1537433)<br>C. (604315, 1537223) | D.(604473, 1536801)<br>E.(604913, 1536874)<br>F.(604568, 1537931) | ១ | ព្រះរំកិល | ថាឡាបរិវ៉ាត់ |
| ១៣ | ភូមិក្រោម | ២៣៥ | A. (604672, 1536145)<br>B. (604775, 1535688)<br>C. (604968, 1535307) | D.(605605, 1534764)<br>E.(605423, 1535703)<br>F.(604591, 1536470) | ១ | ព្រះរំកិល | ថាឡាបរិវ៉ាត់ |
| ១៤ | ភូមិកណ្ដាល | ៨៦ | A. (604473, 1536801)<br>B. (604591, 1536470)<br>C. (604672, 1536145) | D.(605456, 1536236)<br>E.(604913, 1536874) | ១ | ព្រះរំកិល | ថាឡាបរិវ៉ាត់ |
| ១៥ | ភូមិអន្លង់ស្វាយ | ១៥៨ | A. (604568, 1537931)<br>B. (601540, 1540115)<br>C. (600269, 1540012) | D.(603045, 1539609)<br>E.(603407, 1538970)<br>F.(603555, 1537758) | ១ | ព្រះរំកិល | ថាឡាបរិវ៉ាត់ |

បានឃើញ និង ឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ ២០១០

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

**រដ្ឋលេខាធិការ**

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ ២០១០

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

ណៅ ធួក